ញ៉ុក - ថែម

# មហាវេស្សន្តរជាតក



ភាគទី ៥

ផ្សាយចេញពី "[illegible]"
រក្សាសិទ្ធិគ្រប់យ៉ាង
ព.ស ២៥៤៦ គ.ស ២០០២

# មហាវេស្សន្តរជាតក

## ទី ៩

## **កណ្ឌមទ្រីបព្វ**

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

យំ បន វញ្ញា មហាបថវឹ ឧន្នាទេត្វា ព្រាហ្មណស្ស បិយបុត្តេសុ ទិន្នេសុ យាវ ព្រហ្មលោកា ឯកកោលាហលំ ជាតំ តេនាបិ ភិជ្ជិតហទយា វិយ ហិមវន្តវាសិនោ ទេវតាយោ តេសំ ព្រាហ្មណេន នីយមានានំ តំ វិលាបំ សុត្វា មន្តយឹសុ សចេ មទ្ទី សកាលស្សេវ អស្សមំ អាគមិស្សតិ សា តត្ថ បុត្តេ អទិស្វា វេស្សន្តរំ បុច្ឆិត្វា ព្រាហ្មណស្ស ទិន្នភាវំ សុត្វា ពលវសិនេហេន បទានុបទំ ធាវិត្វា មហន្តំ ទុក្ខំ អនុភវេយ្យាតិ ។

យំ សព្វញ្ញុតញ្ញាណំ វីព្រះប្រាថ្នាសពេជ្ជូតាញ្ញាណឯណា វញ្ញា គឺព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ កាលព្រះអង្គតាំងព្រះហឫទ័យប្រាថ្នា តំ សព្វញ្ញុតញ្ញាណំ នូវព្រះប្រាថ្នាសពេជ្ជូតាញ្ញាណនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឯងហើយនៃ ទើបព្រះអង្គបរិច្ចាគ ព្រះរាជបុត្រទាំងពីរជាសម្លាញ់ឱ្យទៅជាទានដល់ព្រាហ្មណ៍ **ជីយមាជាធំ** ព្រាហ្មណ៍ក៏នាំចេញទៅឱ្យព្រាត់ប្រាសចាកសម្ដេចព្រះរាជមទ្រីមាតា ដ៏ជាទានបរមត្ថបារមីនៃព្រះអង្គ ក៏បង្កើតជាអស្ចារ្យក្រឡាមហាប្រឹថពី កក្រើកអំពើកញ្ជាប់ញ័ររៀងរាល់ទៅដល់ព្រហ្មលោកនាយ ។

បពិត្រអើយកាលនោះ ជូជកព្រាហ្មណ៍កំណាច អាចនាំព្រះរាជកុមារតូច ៗ ទាំងពីរព្រះអង្គ ចងនឹងវល្លិហើយនាំបណ្ដើរទៅដោយនូវផ្លូវ ត្រូវក្រួសខ្សាច់ក្ដៅ ដ៏មានព្រះបាទទាំងពីរ ពុរពងរងឈាមនឹងយាងព្រះបាទពុំបាន ។ ព្រាហ្មណ៍ជូសាមាន្យ វាយបណ្ដើរមុខគួរឱ្យអាសូរករុណាព្រះរាជកុមារទាំងគូ ពុំដែលស្គាល់ទុក្ខលំបាកហាលថ្ងៃក្ដៅក្រហាយ ស្រេកទឹក ឃ្លានអាហារ ឯណាព្រាត់ប្រាសចាកព្រះមាតាពុំយល់ភក្ត្រ ដ៏មានព្រះឱរាហាក់ដូចនឹងបែកសញ្ញែកចេញជា ៧ ភាគ ដ៏មានទឹកព្រះនេត្រហូរសស្រាក់សស្រោកស្រោចទាំងពីរព្រះអង្គទ្រង់ព្រះកន្សែងថ្លែងពិលាបមុខគួរឱ្យអាណិតអនាថមហិមា ។ រីនាងកុមារីក្រស្នា ខំទប់ព្រះសោកា ហើយមានបន្ទូលនឹងព្រះជាលីថា

Websites: WatKhemaraRatanaram.org or WatKhmers.org

‹‹បពិត្រអ្នកបងអើយ ឥឡូវនេះ មកយើងនឹងផ្ដាំអស់ទេវតាទាំងឡាយថា បពិត្រទេវតាទាំងឡាយអើយ អ្នកបិតនៅនាព្រៃនេះ ក្រែងព្រះមេយើងមកពីព្រៃ រកយើងពុំឃើញឡើយ ហើយអ្នកនឹងរត់តាមដោយនូវស្នាមជើងនៃយើងមក ក៏សូមឱ្យអស់ទេវតាទាំងឡាយ អ្នកអាសូរព្រមានអ្នកព្រះមេយើងផង ថាយើងទាំងពីរនេះសឹងឥតទុក្ខឥតភ័យ កុំបីអ្នកព្រួយព្រះហឫទ័យ គិតមកដល់យើងទាំងពីរឡើយ›› ។

រីទេវតាផងទាំងឡាយ កាលណាបើបានឮសព្ទទំនួញ ព្រះរាជកុមារទាំងពីរអង្គទ្រង់ព្រះកន្សែង ទៅរកព្រះវររាជមាតា មានព្រះបន្ទូលផ្ដាំដូច្នោះនោះ អស់ទេវតាផងមិនអាចដើម្បីនឹងទប់ទល់នូវសំណោកនោះបានឡើយ ហើយស្រដីនឹងគ្នាថា ម្នាលគ្នាយើងទាំងឡាយអើយ ឥឡូវនេះ ព្រះបរមពោធិសត្វ ព្រះអង្គឱ្យទានព្រះរាជបុត្រសម្លាញ់ទាំងពីរទៅព្រាហ្មណ៍ ហេតុព្រះអង្គចង់ឱ្យបានត្រាស់ ព្រះប្រាជ្ញាសព្វញ្ញុតាញាណ ។ ឯព្រះរាជមទ្រី ស្ដេចទៅព្រៃស្វែងរកមើមឈើ ផ្លែឈើផង ថាបើព្រះនាងមកដល់ពីថ្ងៃ រកព្រះរាជបុត្រពុំយល់ឡើយ ហើយព្រះនាងនឹងទូលដណ្ដឹង កាលណាបើព្រះនាងបាន

Websites: WatKhemaraRatanaram.org or WatKhmers.org

ដំណឹងហើយ សមនឹងក្រាបលាទៅដោយនូវសេចក្ដីស្នេហាអាល័យ ក៏នឹងរត់ទៅតាមព្រះរាជបុត្រ ដ៏មានសំណោកនោះរន្ធត់ក្នុងព្រះហឫទ័យ មានព្រះឱរាក្ដៅផ្សា សមព្រះនាងនឹងទ្រង់ព្រះកន្សែងសង្រេងសង្រៃដរាបលុះក្ស័យព្រះជន្មមិនទេឡើយ ។ ម៉្លោះហើយសមព្រះបរមពោធិសត្វ នឹងទ្រង់ស្រងេះស្រងោចខ្លោចផ្សាក្នុងព្រះឱរាតែមួយព្រះអង្គឯង ។ ឱះឱ ! ថាបើដូច្នោះហើយតើ រីសេចក្ដីពិព្យាយាមឯណាឡើយ ក៏នឹងបានពេញលេញទៅទៀតបាន បើដូច្នោះមានតែយើងធ្វើឧបាយកល កុំឱ្យព្រះនាងមកកាន់អាស្រមពីថ្ងៃបានឡើយ ។ ទេវបុត្រគិតដូច្នោះហើយ ទើបមានបង្គាប់ប្រើទេវបុត្រទាំង ៣ អង្គ រីទេវបុត្រ ១ អង្គនោះ ឱ្យនិម្មិតខ្លួនជារាជសីហ៍, អង្គមួយឱ្យនិម្មិតជាខ្លាធំ, អង្គមួយទៀតឱ្យនិម្មិតជាខ្លាដំបង ឱ្យទៅក្រាបចាំនៅទទឹងផ្លូវចង្អៀត ទោះបីនាងអង្វរលោមទោមសូមផ្លូវដូចម្ដេចក្ដី ក៏កុំអាលបើកផ្លូវឱ្យនាងទៅបានឡើយ ហើយមើលវេលាវិកាល បើព្រះអាទិត្យទន់ទាបហៀបនឹងអស្ដង្គតហើយ សន្សឹមអ្នកទាំងឡាយបើកផ្លូវឱ្យព្រះនាងស្ដេចមក ។ មួយសោត ឱ្យរាំងមើលក្រែងសត្វម្រឹគពាឡយង់ឃ្នងឯណាមួយនឹង

Websites: WatKhemaraRatanaram.org or WatKhmers.org

មកពាធាបៀតបៀនព្រះនាងនោះ ក៏ឱ្យកំចាត់ចេញឱ្យឆ្ងាយ ហើយអ្នកទាំងឡាយ គប្បីពិភ័ក្តិរក្សាព្រះនាងកុំបីប្រហែសឡើយ ល្មើកតែមានសត្វសាហាវឯណាមួយ វាមកពាធាបៀតបៀនព្រះនាងមទ្រីឱ្យក្ស័យព្រះជន្មទៅកាលណា ព្រះវេស្សន្តរបវររាជឥសី ព្រះអង្គជ្រាបសេចក្តីហើយ សមនឹងទ្រង់ព្រះកន្សែងសោកស្រណោះអាឡោះអាល័យព្រះមទ្រីអគ្គមហេសី ជាស្រ្តីមានស្មារតី តែងនឹងធ្វើវត្តប្រណិប័តន៍សព្វថ្ងៃសមនឹងទ្រង់ព្រះសង្រេងសង្រៃក្នុងព្រះឱរា ឯណាព្រះរាជបុត្រាបុត្រី ក៏ពុំយល់ព្រះភក្រ្ត សមអ្នកនឹងរែងជាទុក្ខខ្លោចផ្សាអនាថាកំព្រាតែមួយព្រះអង្គឯង តែងនឹងទ្រង់ព្រះសំណោកនោះពុំដែលដាច់ឡើយ ។ រីក្តីប្រាថ្នាប្រាជ្ញាសព្វេជ្ញតាញាណ ក៏នឹងរសាយរលាយឃ្លាតឆ្ងាយទៅ រីអស់យើងនូវអស់សត្វទាំងអម្បាលម៉ាន ដែលនឹងបានដោយសារព្រះអង្គ ក៏នឹងវិលវល់អំពល់នៅក្នុងវដ្តសង្សារ ។ ប្រការមួយសោត ទោសនឹងមានដល់យើងផងទាំងឡាយអម្បាលនៅក្នុងកំឡុងព្រៃនេះ ព្រះឥន្រ្ទាធិរាជនឹងដៀលថាយើងមើលបំណាំ ពុំបន្ថែមន្ទាំជួយចាំពិភ័ក្តិរក្សាក្សត្រទាំងពីរព្រះអង្គនោះឡើយ ។ ម្លោះហើយអ្នកទាំងឡាយ កុំផ្សូរ

ផ្សងយូរឡើយ ចូរបបួលគ្នាទៅឆាប់ហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ យំ អត្ថំ រីអាថ៌ធម៌ឯណា ន ចាកដំ ពុំទាន់ប្រាកដ សត្ថា រីព្រះសាស្តាចារ្យ បកាសេន្តោ កាលព្រះអង្គទ្រង់ប្រកាស តំ អត្ថំ នូវអាថ៌ធម៌នោះ ចាកដំ ឱ្យប្រាកដ អាហ ក៏ទ្រង់សូត្រសាជាអាថ៌បាទព្រះគាថាដូច្នេះ ៖

តេសំ លាលបិតំ សុត្វា តយោ វាឡា វនេ មិគា
សីហោ ព្យគ្ឃោ ច ទីបិ ច ឥធំ វចនមព្រវុំ ។
មា ហេវ នោ រាជបុត្តី សាយំ ឧញ្ញាតោ អាគមា
មា ហេវម្ហាក និព្ភោគេ ហេបយិត្ថ វនេ មិគា ។
សីហោ ច នំ វិហេបេយ្យ ព្យគ្ឃោ ទីបិ ច លក្ខណំ
នេវ ជាលិកុមារស្ស កុតោ កណ្ហាជិនា សិយា
ឧភយេនេវ ជិយេថ បតិបុត្តេ ច លក្ខណាតិ ។

បពិត្រអើយ អស់ពពួកទេវតា បានស្តាប់សព្ទសំឡេងយោបំព្រះរាជកុមារទាំងពីរអង្គនោះហើយ ពុំលង់ឡើយ ក៏បង្គាប់ទេវបុត្រ ៣ អង្គ ឱ្យតំណែងកាយាជារាជសីហ៍ ខ្លាធំ និងខ្លាដំបង ចាំរាំងពាំងផ្លូវ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះនាងមទ្រីរាជបុត្រី ដើម្បីកុំឱ្យស្ដេចទៅកាន់បណ្ណសាលាពីរសៀល ព្រះសុរិយា រង់ចាំដល់ពេលព្រលប់ សឹមឱ្យស្ដេចត្រឡប់ទៅ ដោយពន្លឺរស្មីនៃដួងព្រះចន្ទ្រ ហើយប្រយ័ត្នរក្សាការពារព្រះនាង កុំឱ្យសត្វសាហាវអ្វីនីមួយមកបៀតបៀនបានឡើយ ។ ប្រសិនបើព្រះនាងដ៏ទ្រទ្រង់នូវលក្ខណា អ្នករាល់គ្នាមិនរក្សាការពារ បណ្ដោយឱ្យរាជសីហ៍ខ្លាធំ ឬខ្លាដំបងបៀតបៀនព្រះនាងឱ្យក្ស័យព្រះជន្មា មុខជាថៅជាលីនិងនាងក្រស្នានឹងក្ស័យព្រះជន្មាពុំខានឡើយ ហើយព្រះវេស្សន្តរជាភស្ដា នឹងគង់នៅឯកាតែមួយព្រះអង្គឯង ម៉្លេះសមព្រះអង្គនឹងលន្លង់លន្លោចខ្លោចផ្សាក្នុងព្រះឱរា ពុំអាចចម្រើនមេត្តាភាវនាតទៅទៀតបានឡើយ ។

បពិត្រអើយ រីទេវបុត្រទាំង ៣ អង្គ កាលបើបានទទួលបង្គាប់ទេវតាជាធំ ពុំយូរឡើយក៏ម្នីម្នាទៅបណ្ដេញសត្វម្រឹគផងទាំងឡាយ មានរាជសីហ៍ជាដើមឱ្យជៀសចេញឆ្ងាយ ហើយអាត្មាឯងនិម្មិតកាយាជាសត្វទាំង ៣ ដូចស្រដីមក ហើយក៏ទៅក្រាបស្រពាបទ្រាបចាំទទឹងផ្លូវព្រះនាងស្ដេចយាងមកនោះឯង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត្រអើយ រីសម្តេចព្រះនាងមទ្រីស្រីរត្នរាជធីតា ស្តេចលីលាទៅស្វែងរកផលាផល កាលណាបើកើតមានកោលាហលអស្ចារ្យ ជានិមិត្តក្នុងព្រះអង្គ ទើបព្រះនាងទ្រង់ព្រះចិន្តាថា ‹‹ឱអញយល់សុបិននិមិត្តយប់មិញនេះអាក្រក់ក្តាត់ បើដូច្នេះគួរអញបេះយកផលាផលនិងមើមឈើផង ទៅកាន់អាស្រមបទពីថ្ងៃ›› ។ ព្រះនាងមានព្រះអង្គញ័រចំប្រប់ ខំឃាងព្រះបាទរកបេះសន្សំផ្លែឈើ នូវមើមឈើបន្តិចបន្តួច ដាក់ក្នុងកញ្ជើគ្រាន់ផ្ញើក្សត្រទាំង ៣ ព្រះអង្គ ហើយព្រះនាងទ្រង់ព្រះកន្សែងបណ្តើរ ទ្រង់រំជួលហាក់ដូចជាមានភិតភ័យក្នុងព្រះរាជហឫទ័យ ហើយជ្រនីក ទំពក់ ក៏ជ្រុះពីព្រះហស្ត កញ្ជើ សង្រែកក៏ភ្លាត់របូតចេញពីព្រះអង្សា ព្រះនេត្រាខាងឆ្វេងរកាំ ព្រះនេត្រាខាងស្តាំកម្រើក មួយសោត រីឈើឯណាដែលឥតផ្លែក៏ខ្វៃប្រែជាមានផ្លែទុំខ្ចីឈើឯណាដែលមានផ្លែទុំខ្ចី ក៏ខ្វៃប្រែជាឥតផ្លែវិញហោង ។ គ្រានោះមហាមេឃក៏មមីរស្រទំសព្វទិសា ព្រះនាងទ្រង់ព្រះចិន្តាថា ‹‹ឱសព្វថ្ងៃមកនោះ អញពុំដែលយល់ដូច្នេះទេ ទើបតែក្នុងថ្ងៃនេះឯង នឹងមានហេតុអ្វីក៏មកយល់ចម្លែកដល់ម្ល៉េះ ឬមួយនឹងមានហេតុភេទអន្តរាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដល់ខ្លួនអញ ឬកូនអញទាំងពីរ ឬមួយនឹងមានដល់ព្រះបាទស្រីវេស្សន្តរជាអម្ចាស់អញ›› ។ ព្រះនាងទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបទ្រង់ព្រះកន្សែងពិលាបថា ៖

ខណិត្តិកំ មេ បតិតំ    ទក្ខិណក្ខិ ច ផន្ទតិ
អផលា ផលិនោ រុក្ខា    សព្វា មុយ្ហន្តិ មេ ទិសា ។
តស្សា សាយណ្ហកាលស្មិំ    អស្សមាគមនំ បតិ
អត្ថង្គតម្ហិ សុរិយេ    វាឡា បន្ថេ ឧបដ្ឋហុំ ។
នីចេ ចោលម្ពតេ សុរិយេ    ទូរេ ច វត អស្សមោ
យញ្ច នេសំ ឥតោ ហិស្សំ    តន្តេ ភុញ្ជេយ្យុ ភោជនំ ។
សោ នូន ខត្តិយោ ឯកោ    បណ្ណសាលាយ អច្ឆតិ
តោសេន្តោ ទារកេ ឆាតេ    មមំ ទិស្វា អនាយតឹ ។
តេ នូន បុត្តកា មយ្ហំ    កបណាយ វរាកិយា
សាយំ សំវេសនាកាលេ    ខីរបីតាវ អច្ឆរេ ។
តេ នូន បុត្តកា មយ្ហំ    កបណាយ វរាកិយា

Websites: WatKhemaraRatanaram.org or WatKhmers.org

សាយំ សំវេសនាកាលេ　　ភរិបីតាវ អច្ឆរេ ។
តេ នូន បុត្តកា មយ្ហំ　　កបណាយ វរាកិយា
បច្ចុក្កតា មំ តិដ្ឋន្តិ　　វច្ឆា ពលាវ មាតរំ ។
តេ នូន បុត្តកា មយ្ហំ　　កបណាយ វរាកិយា ។
បច្ចុក្កតា មំ តិដ្ឋន្តិ　　ហំសាវុបរិបល្លលេ
តេ នូន បុត្តកា មយ្ហំ　　កបណាយ វរាកិយា ។
បច្ចុក្កតា មំ តិដ្ឋន្តិ　　អស្សមស្សាវិទូរតោ
ឯកាយនោ ឯកបថោ　　សរា សោព្ភា ច បស្សតោ
អញ្ញំ មគ្គំ ន បស្សាមិ　　យេន គេច្ឆេយ្យ អស្សមំ ។
មិគា នមត្ថុ រាជានោ　　កាននស្មឹ មហាពលា
ធម្មេន ភាតរោ ហោថ　　មគ្គំ មេ ទេថ យាចិតា
អវរុទ្ធស្សាហំ ភរិយា　　រាជបុត្តស្ស សិរីមតោ ។
តញ្ចាហំ នាតិមញ្ញាមិ　　រាមំ សីតាវនុព្វតា
តុម្ហេ ច បុត្តេ បស្សេថ　　សាយំ សំវេសនំ បតិ

Websites: WatKhemaraRatanaram.org or WatKhmers.org

អហញ្ច បុត្តេ បស្សេយ្យំ ជាលិំ កណ្ហាជិនំ ចុភោ ។
ពហុញ្ចិជំ មូលផលំ ភក្ខោ ចាយំ អជប្បកោ
តតោ ឧបឌ្ឍំ ឧស្សាមិ មក្កំ មេ ទេថ យាចិតា ។
រាជបុត្តី ច វោ មាតា រាជបុត្តោ ច វោ បិតា
ជម្មេន ភាតរោ ហោថ មក្កំ មេ ទេថ យាចិតាតិ ។

ឱ ! អញអស្ចារ្យចម្លែកអ្វីមាល្បាយ ជ្រនីកក៏ជ្រុះរបូតពីដៃ ភ្នែកខាងស្តាំអញក៏កម្រើកញឹក ៗ ដើមឈើណាដែលធ្លាប់មានផ្លែ ជាពន្លឹក ក៏ប្រែខ្វៃជាឥតផ្លែវិញ ឯអាកាសក៏ងងឹតអ័ព្ទទិសា ហើយព្រះនាងទ្រង់ព្រះកន្សែងបណ្តើរ ព្រះនេត្រាគយគន់មើលទៅព្រះអាទិត្យ ទ្រង់ព្រះចិន្តាថា «ឱ សុរិយាក៏រសៀលរវៀលទន់ទាបទៅហើយ និមិត្តក៏កើតមានប្រាកដ បើដូច្នោះអញកុំនៅយូរឡើយ ត្រឡប់ទៅពីថ្ងៃបន្តិចក៏បានអេះ» ។ ម្ល៉ោះហើយ ក្នុងព្រះរាជហឫទ័យនៃព្រះនាងតែងនឹងទ្រង់បារម្ភគិតជញ្ជឹងរំពឹងទៅក្សត្រទាំង ៣ ព្រះអង្គ ។ ព្រះនាងទ្រង់ព្រះកន្សែងបំភ្លាងឃាងព្រះបាទបណ្តើរ ព្រះនេត្រតែងនឹងទ្រង់ឆៀងមៀងមើលដោយនូវផ្លូវដំណើរ លុះដល់ទៅច្រកចង្អៀត

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្រាប់ តែពើបពះប្រទះនឹងសត្វទាំងបី ក្រាបយកសិរសីប្រឈមមក កាន់ព្រះនាង ហើយគ្រហឹមគម្រាមដ៏មានស័ព្ទខ្ទ័រខ្ទារ ញ័រទាំងប្រឹថពី មុខគួរឱ្យអាសូរប្រណី សម្ដេចព្រះនាងមទ្រីក្សត្រីក៏ទ្រង់ភ្ញាក់ភិតភាំង ស្រឡាំង កាំង តក់ស្លុត់លុតជង្គង់ចុះផ្ទង់តម្រង់ព្រះស្មារតី សម្ដេច ក្សត្រីព្រះនាងលើកព្រះហស្ដទាំងពីរប្រណម្យ ហើយមានព្រះបន្ទូល អង្វរលោមថា ‹‹បពិត្រអ្នកដ៏ជាត្រកូលរាជម្រឹគប្រសើរអើយ អ្នកហោង មានឫទ្ធិអានុភាពក្រៃលែង ម្រឹគសត្វចតុប្បាទទាំងឡាយនៅនាភ្នំគីរី វង្កតនេះ អ្នកតែងមានមេត្តាដល់យើង ។ រីព្រះបាទស្រីវេស្សន្តរបវររាជ ត្រកូល ចូលមកកសាងព្រះផ្នួសបួសជាតាបស មានតែខ្ញុំជាសិស្សមក នៅប្រណិប័តន៍សព្វថ្ងៃ ឥឡូវនេះជួបវេលារិកាលនឹងសោយផលា-ហារ អញខ្ញុំនឹងនាំទៅថ្វាយព្រះអង្គនាព្រះបរមសាលា ក៏សូមអម្ចាស់ ទាំងឡាយ អ្នកមេត្តាបើកផ្លូវឱ្យអញខ្ញុំ ទៅឰដ៏កាលឥឡូវនេះឯង ហោង›› ។

រីសត្វទាំងបី កាលណាបើឮព្រះសវនីយ៍ព្រះនាងអង្វរ ប៉ុន្មាន ៗ ក្ដី មិនអាចដើម្បីនឹងបើកផ្លូវឱ្យឡើយ ហើយរឹងធ្វើជាគម្រាម

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះមហិមាក្រៃពេក ។ រីព្រះនាងមទ្រីយល់សត្វទាំងបីគម្រាមដូច្នោះហើយ ក៏មានព្រះអង្គនោះញ័ររន្ធត់ រមិលរកផ្លូវនឹងគេចរត់ជៀសចេញពុំបានឡើយ ហើយព្រះនាងទ្រង់ព្រះកន្សែង គិតក្រែងម្រឹគទាំងបីបៀតបៀនឱ្យក្សិណក្ស័យព្រះជន្មា សមព្រះរាជស្វាមីនូវព្រះរាជបុត្រទាំងពីរនឹងកំព្រា ទើបព្រះនាងទ្រង់ព្រះកន្សែងពិលាបថា «ឱអម្ចាស់ខ្ញុំអើយ ចាប់ដើមតាំងអំពីខ្ញុំបានមកជាបាទបរិចារិកា បំរើព្រះអង្គកាលគង់នៅនគរនាយឡើយ អម្ចាស់រែងតែងទ្រង់ព្រះមេត្តាអញខ្ញុំមទ្រី មិនឱ្យអន់អាក់ថ្នាក់ចិត្តឡើយ លុះចេញចាករាជសម្បត្តិទាំង ៤ ព្រះអង្គមកគង់នៅនាព្រៃភ្នំគិរីវង្កតបពិតនេះ អញខ្ញុំតែងនឹងស្វែងរកផ្លែឈើបម្រើតែសព្វថ្ងៃ ឥតបីមានភ័យភិតគិតក្រែងសត្វម្រឹគបក្សីឯណាមួយនឹងមកបៀតបៀននោះឡើយ ។ អម្ចាស់ខ្ញុំអើយ ឥឡូវនេះ ខ្ញុំអម្ចាស់មានភ័យនឹងព្រះរាជម្រឹគទាំងបី មកខាំងរាំងផ្លូវនឹងទៅពុំរួចឡើយ ថាបើអម្ចាស់ជ្រាបជាខ្ញុំមានភ័យហើយ សមស្តេចនឹងមកអង្វររាជម្រឹគទាំងបី ឱ្យខ្ញុំបានទៅយល់កូនខ្ញុំទាំងពីរមិនទេឡើយ ។ ឱ អម្ចាស់ខ្ញុំអើយ បើឥតនឹងខ្ញុំហើយ នរណាឡើយនឹងប្រណិប័តន៍ ។ ឱ អម្ចាស់ខ្ញុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

អើយ វេលាថ្ងៃនេះហើយ ព្រះអង្គរែងសោយផលាហារត្រអាលនឹងបុត្រទាំងពីរ ។ ឱកូនសំឡាញ់ទាំងពីរអើយ ថ្ងៃល្ងាចត្រជាក់ថ្ងៃនេះហើយ អ្នកតែងនឹងបណ្តើរគ្នាមកលេងឯក្រៅ ចាំមើលផ្លូវម្តាយ បើបានឃើញជាក់ជាម្តាយហើយ សឹងរត់ពីចម្ងាយប្រណាំងប្រជែង ប្រកៀកប្រកៀងមកទទួលម្តាយសព្វថ្ងៃ ។ ឱ កូនសំឡាញ់ទាំងគូអើយ កាលបើម្តាយបានយល់ស្ងួនសម្លាញ់ រត់ប្រដេញគ្នាមកកាន់ម្តាយ រីទុក្ខផងទាំងឡាយ ក៏រសាយរលាយបាត់អស់ ទោះសេចក្តីនឿយព្រួយក្តៅក្រហាយនឿយហត់ ក៏បាត់ទៅឯង ហើយម្តាយម្ទឹម្ទាដាក់អម្រែកចេញពីស្មា ដៃស្រវាឱបអ្នកទាំងពីរ រីនាងស្រីក្រស្នាកូនពៅពុំងា តែងនឹងស្រវាឱបម្តាយ ស្រដីនិយាយតាមដោយភាសាជាក្មេង ហើយសូមដោះបៅ រីចៅជាលីកូនប្រុសពិសី រែងតែងនឹងស្រដីនិយាយនឹងម្តាយ ហើយប្រវារកផ្លែឈើឯណាទុំ ៗ ល្អ ហើយបរិភោគបំភ្លាង ដៃម្ខាងបង្អួតបង្អរប្អូន កូនអើយឥឡូវនេះ សមអ្នកចេញមកមើលផ្លូវម្តាយដឹងអើយ បើយល់បាត់ពន់វេលា កាលពុំឃើញម្តាយឡើយ សមអ្នកនឹងស្រែកយំ នាំគ្នាចូលទៅកាន់ព្រះអាស្រមបទបរមសាលា នឹងអង្វរព្រះ

វររាជបិតាថា អ្នកម្តាយខ្ញុំបាត់ពន់វេលាកាល សូម្បីព្រះវររាជបិតា នឹងបបក់ព្រលឹងបបោសផាត់ផង់ធូលី ហើយល្បួងលោមឱ្យបរិភោគនូវផ្លែឈើ មើមឈើ អម្បាលដែលសំណល់សល់នៅនោះហើយ អ្នកក៏នៅតែឃំជាទុក្ខខ្សឹកខ្សួល រអាក់រអួលក្នុងឱរា លុះត្រាតែនឿយហើយផ្ទំលក់ទៅហោង ។

អថ តយោ ទេវបុត្តា រីទេវបុត្រទាំង ៣ អង្គ ដែលនិម្មិតអាត្មាជាសត្វទាំង ៣ កាលបើគន់មើលពេលវេលាដឹងថា ឥឡូវនេះ ជាវេលាសមគួរនឹងបើកផ្លូវឱ្យព្រះនាងហើយ ទើបនាំគ្នាក្រោកដោះឡើង ហើយគេចជៀសចេញពីផ្លូវនោះទៅ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាជាបាទព្រះគាថាទាំងឡាយដូច្នេះ ៖

តស្សា លាលប្បមានាយ ពហុំ ការុញ្ញសញ្ហិតំ
សុត្វា នេលបតី វាចំ វាឡា បន្ថា អបក្កមុន្តិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ភិក្ខុវេ ម្នាលសង្ឃដ៏ទ្រង់នូវ សីល សមាធិ បញ្ញា រីទេវបុត្រទាំង ៣ អង្គ ដែលទ្រង់និម្មិតជាសត្វទាំង ៣ កាលណាបើបានស្តាប់ព្រះសវនីយ៍ព្រះនាងមទ្រី មានព្រះបន្ទូលអង្វរសូមផ្លូវជាច្រើនដងច្រើនគ្រា ហើយដល់វេលាវិកាលផង ។ ឯថ្ងៃដែលព្រះបរមពោធិសត្វឱ្យទានព្រះរាជកុមារនោះ ជាថ្ងៃពេញបូណ៌មីឧបោសថ ចូលជាព្រះអាទិត្យអស្តង្គតផុតរស្មីទៅហើយ ព្រះចន្ទ្ររង្សីក៏រឿងរះ ស្រឡះពពកមកពីបូព៌ាទិស ដ៏មានអស់ពពួកតារាហែហមចោមរោមជាបរិវារ យល់កាលសមគួរនឹងបើកមាគ៌ាឱ្យព្រះនាង ទើបនាំគ្នាជៀសចេញទៅកាន់ឋានវិមានអាត្មាទីទៃ ៗ វិញហោង ។

ឥមម្ហិ ជំ បទេសម្ហិ　　　　ឲុត្តកា បំសុកុណ្ឋិតា
បច្ចុគ្គតា មំ តិដ្ឋន្តិ　　　　វគ្ឃា ពាលាវ មាតរំ ។
ឥមម្ហិ ជំ បទេសម្ហិ　　　　ឲុត្តកា បំសុកុណ្ឋិតា
បច្ចុគ្គតា មំ តដ្ឋិន្តិ　　　　ហំសាវុបរិបល្លេ ។
ឥមម្ហិ ជំ បទេសម្ហិ　　　　ឲុត្តកា បំសុកុណ្ឋិតា
បច្ចុគ្គតា មំ តដ្ឋន្តិ　　　　អស្សមស្សាវិទូរតោ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

តេ មិគា វិយ ឧក្កណ្ណា សមន្តាមភិធាវិនោ
អានន្ទិនោ បមុទិតា វត្តមានាវ កម្បរេ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលិំ កណ្ហាជិនំ ចុភោ ។
ឆគិលីវ មិគី ឆាបំ បក្ខី មុត្តាវ បញ្ជរា
ឱហាយ បុត្តេ និក្ខម្ម សីហីវាមិសគិទ្ធិនី
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលិំ កណ្ហាជិនំ ចុភោ ។
ឥទំ នេសំ បទក្កន្តំ នាគានមិវ បព្វតេ
ចិតកា បរិកិណ្ណាយោ អស្សមស្សាវិទូរតោ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលិំ កណ្ហាជិនំ ចុភោ ។
វាលុកាយបិ ឱកិណ្ណា បុត្តកា បំសុកុណ្ឋិតា
សមន្តាមភិធាវន្តិ តេ ន បស្សាមិ ទារកេ ។
យេ មំ បុរេ បច្ចុទេន្តិ អរញ្ញា ទូរមាយតិំ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលិំ កណ្ហាជិនំ ចុភោ ។
ឆគិលីវ មិគី ឆាចា បច្ចុគ្គន្ត្វាន មាតរំ
ទូរេ មំ បដិវិលោកេន្តិ តេ ន បស្សាមិ ទារកេ ។

ឥទញ្ច នេសំ កីឡនំ បតិតំ បណ្ឌុវេលុវំ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលឹ កណ្ហាជិនំ ចុភោ ។
ថណា ច មយ្ហ មេ បូរា ឧរោ ច សម្បទាលតិ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលឹ កណ្ហាជិនំ ចុភោ ។
ឧច្ឆង្គេមេកោ វិចិនតិ ថណោ មេការ លម្ពតិ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលឹ កណ្ហាជិនំ ចុភោ ។
យស្សា សាយណ្ហសមយំ បុត្តកា បំសុកុណ្ឋិតា
ឧច្ឆង្គេ មេ វិត្តន្តិ តេ ន បស្សាមិ ទារកេ ។
អយំ សោ អស្សមោ បុព្វេ សមជ្ជោ បដិភាតិ មំ
ត្យជ្ជ បុត្តេ អបស្សន្ត្យា ភមតេ វិយ អស្សមោ ។
កិមិទំ អប្បសទ្ទោវ អស្សមោ បដិភាតិ មំ
កាកោលាបិ ន វស្សន្តិ មតា មេ នូន ទារកា ។
កិមិទំ អប្បសទ្ទោវ អស្សមោ បដិភាតិ មំ
សកុណាបិ ន វស្សន្តិ មតា មេ នូន ទារកាតិ ។

ឮដ៏កាលនោះ ព្រះនាងមទ្រីក្សត្រីប្រសើរ ព្រះនាងយល់សត្វទាំង ៣ អន្តរធានបាត់ទៅហើយ ព្រះនាងត្រេកអរម្ទីម្នា ប្រវាចាប់

Websites: WatKhemaraRatanaram.org or WatKhmers.org

បានដងវែកដាក់លើព្រះអង្សា ព្រះនាងលីលាមកដោយពន្លឺព្រះចន្ទ្រ លុះព្រះនាងយាងទៅដល់ឋានចង្រ្កមណ៍ យល់ស្ងាត់ច្រៀបច្រងំក្រៃពេក ប្លែកនឹងសព្វថ្ងៃ ព្រះនាងក៏អួលអាក់ក្នុងព្រះហឫទ័យ ទ្រង់ព្រះកន្សែងថា៖ «ឱឋានទីនេះហើយ កូនស្ងួនសម្លាញ់ម្ដាយទាំងពីរ តែងនៅលេងធូលីដី ឈរចាំមើលផ្លូវម្ដាយមកពីព្រៃ បើឃើញម្ដាយមកពីចម្ងាយ ក៏ម្នីម្នារត់ទៅទទួលម្ដាយ បីដូចកូនគោរត់រកមេវា ពុំនោះសោតបីដូចកូនហង្សនៅលើកក់រង់ចាំមើលផ្លូវមេវា ឱកូនពុំងាម្ដាយអើយ អ្នកទាំងពីរតែងមកឈរចាំទទួលម្ដាយនៅជិតព្រះអាស្រម ។ សព្វថ្ងៃមកម្ដាយធ្លាប់ឃើញកូនស្ងួនទាំងពីររត់មកទទួល មានអាការរីករាយសប្បាយចិត្ត រត់រលះរលាំងនៅជុំវិញខ្លួនម្ដាយ បីដូចកូនម្រឹគរត់ឆ្លេឆ្លានៅជុំវិញមេវា មកថ្ងៃនេះ ម្ដាយមិនបានឃើញបាជាលី និងមេក្រស្នាកូនស្ងួនទាំងគូរបស់ម្ដាយឡើយ ។ ម្ដាយនេះ លះបង់កូនទាំងពីរចេញទៅស្វែងរកអាហារ ឧបមាបីដូចមេពពែ ឬមេម្រឹគ ឬមេបក្សីលះបង់កូនខ្ចីឱ្យនៅក្នុងសំបុក ពុំនោះសោត បីដូចមេសិង្ហដែលមានចិត្តអន្ទះអន្ទែង ចេញទៅស្វែងរកអាហារ លះបង់កូនតូច ៗ ហើយខ្លួន

Websites: WatKhemaraRatanaram.org or WatKhmers.org

ឯងចេញទៅរកស៊ី ។ នេះហើយជាស្នាមជើងដែលកូនទាំងពីររត់លេង បន្លែងគ្នា មានស្នាមប្រាកដដូចជាស្នាមសត្វហាត្ថិលិង្គនៅក្នុងច្រកភ្នំក្នុង រដូវភ្លៀងនេះ ជាគំនរខ្សាច់ដែលអ្នកទាំងពីរជញ្ជូនមកពូនលេងរោយ រាយនៅជិតព្រះអាស្រម ថ្ងៃនេះម្ដាយមិនបានរីករាយសប្បាយចិត្ត ត្បិតបាត់មុខអ្នកទាំងពីរទៅ ។ សព្វថ្ងៃមកនោះ កូនស្ងួនទាំងគូ ទុកជា ប្រឡាក់ដីខ្សាច់និងផង់ធូលីដី គ្រាន់តែក្រឡេកឃើញម្ដាយមកពីព្រៃ ក៏ រត់មកទទួលម្ទីម្នា ថ្ងៃនេះម្ដាយស្រងេះស្រងោចខ្លោចចិត្ត ត្បិតបាត់មុខ កូនទាំងគូទៅ ។ សព្វថ្ងៃមក កូនស្ងួនតែងចាំទទួលម្ដាយ ដែលត្រឡប់ មកពីព្រៃឆ្ងាយ ថ្ងៃនេះម្ដាយមិនបានឃើញមុខជាលីមេក្រស្នា កូនទាំង ពីរឡើយ ។ សព្វថ្ងៃមក កូនស្ងួនតែងចាំមើលផ្លូវម្ដាយបីដូចកូនពពែ ឬ កូនម្រឹគដែលងើបរកមេវា ថ្ងៃនេះម្ដាយមិនបានឃើញមុខកូនទាំងពីរ ឡើយ ។ ឱ នេះនៃផ្លែព្នៅទុំសម្បុរដូចមាស កូនស្ងួនម្ដាយធ្លាប់បីលេង ម្ដេចក៏មកធ្លាក់ខ្ចាត់ខ្ចាយនៅទីនេះ។ ឱដោះម្ដាយទាំងគូពោរពេញទៅ ដោយទឹកដោះ ដើមទ្រូងម្ដាយស្ទើរប្រេះធ្លាយ ។ អ្នកណាអើយនឹងមក ប្រទាញប្រទង់ជាយសំពត់ម្ដាយ អ្នកណាអើយនឹងមកចាប់អង្អែល

Websites: WatKhemaraRatanaram.org or WatKhmers.org

ដោះម្ដាយ (សុំដោះថៅ) វេលាល្ងាចកូនស្ងួនតែងប្រឡាក់ដីខ្សាច់ស្រម៉ក រត់មកចាប់ទាញជាយសំពត់ម្ដាយ ថ្ងៃនេះមិនបានឃើញមុខស្ងួនឡើយ ។ កាលពីមុនមក ព្រះអាស្រមនេះប្រាកដដូចជាមានតូរ្យតន្ត្រីមហោស្រព ថ្ងៃនេះម្ដាយមិនបានឃើញមុខកូនកំសត់ ទើបប្រាកដដូចអកាលវិលនៃប៉ែនព្រមស្ងួនផ្ទាំង ឱព្រះអាស្រមបទ ម្ដេចក៏ស្ងប់ស្ងាត់អ្វីម្ល៉េះ សូម្បីសត្វតាវៅ និងហ្វូងសត្វស្លាបក្នុងព្រៃស្តុក ក៏មិនមានយំរងាវរកគ្នាសោះឡើយ កូនសម្លាញ់ម្ដាយប្រហែលជាស្លាប់បាត់បង់ទៅហើយដឹងអើយ ! ។

សម្ដេចព្រះនាងមទ្រី ទ្រង់ព្រះកន្សែងពិលាបសោយសោកអាមោក្ខពេកក្រៃ ទើបទ្រង់ព្រះចិន្តាថា ក្រែងថៅជាលីនិងមេក្រស្នាទៅនៅឯព្រះវររាជបិតា ទើបព្រះនាងលីលាទៅកាន់ព្រះអាស្រមបរមសាលា ដាក់អម្រែកពីព្រះអង្សា ទតឃើញព្រះពោធិសត្វ គង់ស្ងៀមមិនមានព្រះវាចា ទាំងមិនបានឃើញព្រះរាជឱរសព្រះរាជធីតា ក្នុងសំណាក់ព្រះមហាសត្វឡើយ ទើបព្រះនាងលុតជង្គង់លើកកម្បង់អញ្ជលីប្រណម្យដាក់លើព្រះសិរសា ហើយដណ្ដឹងព្រះបរមពោធិសត្វ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដោយបាទព្រះគាថាដូច្នេះ ៖

គិមិទំ តុណ្ហីភូតោសិ    អបិ រត្តេវ មេ មនោ
កាកោលាបិ ន វស្សន្តិ    មតា មេ នូន ទារកា ។
គិមិទំ តុណ្ហីភូតោសិ    អបិ រត្តេវ មេ មនោ
សកុណាបិ ន វស្សន្តិ    មតា មេ នូន ទារកា ។
កច្ចិ នុ មេ អយ្យបុត្ត    មិគា ខាទឹសុ ទារកេ
អរញ្ញេ ឥរិណេ វិវនេ    កេន នីតា មេ ទារកា ។
អាទុ តេ បហិតា ទូតា    អាទុ សុត្តា បិយំ វទា
អាទុ ពហិ នោ និក្ខន្តា    ខិឌ្ឌាសុ បសុតា នុ តេ ។
នេវាសំ កេសា ទិស្សន្តិ    ហត្ថចាទា ច ជាលិនោ
សកុណានញ្ច ឱចាតោ    កេន នីតា មេ ទារកាតិ ។

បពិត្រព្រះរាជស្វាមីអម្ចាស់ខ្ញុំអើយ ហេតុអ្វីក៏ទ្រង់គង់ស្ងៀម ទ្រមឹងពុំមានព្រះបន្ទូល ចិត្តអញខ្ញុំញាប់ញ័រចំប្រប់ដូចក្នុងកាលយប់ ដែលបានយល់សប្តិឃើញនិមិត្តអាក្រក់អប្រិយ សូម្បីក្អែកព្រៃនិងសត្វបក្សាបក្សី ក៏មិនឮស្នូរយំរងាវ កូនកំសត់របស់អញខ្ញុំ ប្រហែលជា

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្លាប់បាត់បង់ទៅទេដឹងអើយ ។ បពិត្រព្រះអយ្យបុត្តជាម្ចាស់អើយ ឬមួយម្រឹគសាហាវយង់ឃ្នងពាំនាំកូនអញខ្ញុំ យកទៅស៊ីហើយ ឬមួយមានអ្នកណាមួយនាំចូលទៅក្នុងព្រៃជ្រៅ ឬនាំចូលទៅក្នុងវាលធំដាច់ស្រយាលដឹងអើយ ឬមួយព្រះអង្គយល់ថៅជាលីចេះសំដីនិយាយពីរោះស្តាប់ ហើយទ្រង់ចាត់ប្រើឱ្យធ្វើជារាជទូត ទៅកាន់សំណាក់ព្រះរាជអយ្យកោឯជេតុត្តរនគរ ឬមួយកូនសំឡាញ់ទាំងគូ ចូលទៅផ្ទំលក់ខាងក្នុងបណ្ណសាលា ឬមួយនាំគ្នាដើរទៅលេងខាងក្រៅបណ្ណសាលា សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស ប្រាប់អញខ្ញុំមទ្រី ឱ្យបានដឹងផងសោះសង្ស័យ សូម្បីតែសរសៃព្រះកេសានិងព្រះហស្ត ព្រះបាទរបស់កូនស្ងួនសម្លាញ់ម្តាយទាំងពីរក៏មិនប្រាកដ ឬមួយសត្វហាត្ថីលិង្គស-កុណជាតិឯទៀត ៗ ឆាបពាំនាំយកទៅបរិភោក្កា អញខ្ញុំសូមទូលសួរព្រះអង្គ តើនរណានាំយកកូនខ្ញុំទាំងគូទៅបាត់ទៅ ? ។

សូម្បីសម្តេចព្រះនាងមទ្រី ក្រាបទូលដណ្តឹងសួរប៉ុន្មាន ៗ ក្តី ព្រះមហាសត្វនឹងមានព្រះបន្ទូលតបទៅដល់មួយព្រះឱស្ឋនោះគ្មានឡើយ ម្លោះហើយ ព្រះនាងរែងជាទុក្ខត្រួតថែមជាទ្វេភាព ទើបក្រាប

Websites: WatKhemaraRatanaram.org or WatKhmers.org

បង្គំទូលសួរតទៅទៀតថា បពិត្រព្រះសម្មតិទេព ចុះហេតុអ្វី ក៏ព្រះអង្គមិនមានព្រះបន្ទូលនឹងអញខ្ញុំ ៗ មានទោសកំហុសដូចម្ដេច ។ ហើយព្រះនាងក្រាបទូលដោយបាទព្រះគាថាដូច្នេះថា ៖

ឥទំ តតោ ទុក្ខតរំ សល្លវិទ្ធោ យថា វណោ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលិំ កណ្ហាជិនំ ចុតោ ។
ឥទំបិ ទុតិយំ សល្លំ កម្បេតិ ហទយំ មម
យញ្ច បុត្តេ ន បស្សាមិ ត្វញ្ច មំ នាភិភាសសិ ។
អជ្ជ ចេ មេ ឥមំ រត្តឹ រាជបុត្ត ន សំសសិ
មញ្ញេ ឱក្កន្តសន្តំ មំ បាតោ ទក្ខសិ នោ មតន្តិ ។

បពិត្រព្រះរាជស្វាមីជាអម្ចាស់អើយ រីទុក្ខអញខ្ញុំគ្រានេះរឹងធ្ងន់ពន់ប្រមាណ ជាងទុក្ខដែលគេបំបរបង់មកនៅព្រៃភ្នំនេះទៅទៀត ព្រោះបាត់បង់ខានយល់មុខកូនទាំងពីរ គឺចៅជាលីនិងមេក្រស្នា តែគឺមោះគ្រាន់អធ្យាស្រ័យ ឯព្រះអង្គពុំមានព្រះបន្ទូលផងនេះ ជាទុក្ខធ្ងន់ពន់ពេកក្រៃ ហាក់ដូចជាព្រះអង្គយកភ្លើងមកដុតអញខ្ញុំ ដែលកំពុងមានភ្លើងឆេះស្រាប់ហើយ ពុំនោះសោត បីដូចទ្រង់យកដំបង

Websites: WatKhemaraRatanaram.org or WatKhmers.org

វាយថៃមនូវអញខ្ញុំ ដែលធ្លាក់ចុះមកពីចុងត្នោត ឬបីដូចទ្រង់យកព្រួញចាក់ថៃម លើដំបៅដែលឈឺផ្សារ ។ បេះដូងរបស់អញខ្ញុំនេះញាប់ញ័រចំប្រប់ និងឈឺក្តៅផ្សា គួរនាបីដូចអ្នកយកកាំទ្រាបលាបអាសិរពិសចាក់តម្រង់ត្រង់លើថ្លើមជម្ងឺ ថ្ងៃនេះអញខ្ញុំក្តៅចិត្តខ្លោចផ្សាត្បិតមិនបានឃើញមុខថៅជាលីនិងមេក្រស្នា ថៃមទាំងព្រះអង្គពុំមានត្រាស់ព្រះវាចានឹងអញខ្ញុំផងសោះ ទុក្ខនេះរឹងធ្ងន់ក្រៃលែង ។ បពិត្រព្រះរាជស្វាមីអម្ចាស់ខ្ញុំអើយ ប្រសិនបើក្នុងយប់នេះ ពុំទ្រង់មានព្រះបន្ទូលប្រាប់ហេតុដល់អញខ្ញុំទេ មុខជាព្រឹកស្អែកនេះ ព្រះអង្គនឹងទតឃើញអញខ្ញុំក្សិណក្ស័យជីវិតិន្ទ្រិយបាត់បង់ទៅទៀងប្រាកដហោង ។

អ៥ មហាសត្តោ កាលនោះ ព្រះមហាសត្វទ្រង់ព្រះសណ្តាប់ព្រះនាងមទ្រី ទ្រង់ព្រះកន្សែងថ្លែងព្រះពិលាប ព្រះអង្គមានព្រះរាជហឫទ័យអាណិតអនាថមហិមា ទើបទ្រង់ព្រះចិន្តាថា បើអញនៅតែស្ងៀមដូច្នេះ សមព្រះនាងនឹងបែកថ្លើមក្ស័យជីវិត ប្រាកដពុំខាន ។ បើដូច្នេះ គួរអញនិយាយសំដីអ្វីឱ្យឈឺចិត្ត ទើបនឹងស្រោកស្រាលស្រយាលទុក្ខបានខ្លះ មានតែអញធ្វើជាស្រដី នូវពាក្យប្រចៃ

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រច័ណ្ឌ ទ្រគោះរឹងរូសប្រឈ្លោះផងទើបនឹងឈឺចិត្ត ។ ទ្រង់ព្រះចិន្តាស្រេចហើយ ទើបស្តេចបែរព្រះភក្ត្រមកកាន់ព្រះនាងមទ្រី ធ្វើជាទ្រង់ខ្ញាល់មានព្រះបន្ទូលថា ៖

ននុ មទ្ទី វរារោហា     រាជបុត្តី យសស្សិនី
ចាតោ កតាសិ ឧញ្ញាយ     តាមិមំ សាយមាគតាតិ ។

ឱមទ្រីនាងអើយ បងអរគុណនាងដែលយកចិត្តឈឺឆ្អាលសង្ខាតលះបង់ព្រះញាតិវង្សា លីលាមកនៅបំរើប្រណិប័តន៍តែសព្វថ្ងៃ នាងសោតជាត្រកូលក្សត្រ ដ៏ទ្រង់នូវរូបឆោមលោមពណ៌សម្បុរល្អិតល្អប្រពៃហៅបញ្ចពិធកល្យាណី ជាស្ត្រីឧត្តមសមនូវនរលក្សណ៍ គន់ទៅមុខមានស្រីស្ងួស្តី មាត់ប្រិមប្រិយ កាលបើស្រដីមុខគួរឱ្យចង់ស្តាប់ ទ្រង់នូវរូបល្អចំណាប់គាប់ចិត្តអ្នកផងៗ បានយល់ហើយ គួរឱ្យពិតពិលរមិលមើលថាជាស្ត្រីប្រសើរ នាមនាងមទ្រីជាអគ្គមហេសីល្បីឮទូទ័រប្រាកដ ពីមុនមក បងរែងគិតថា នាងមានកិរិយាមារយាទក្នុងជាតិនេះនឹងបានជាគូសាងសម្ភារបារមីទៅឰដ៏អនាគតកាល ទុកចិត្តស្និទ្ធស្នាលបណ្តែតបណ្តោយឱ្យត្រអាលតាមចិត្តសប្បាយ ពុំដឹងជានាងមានកល

Websites: WatKhemaraRatanaram.org or WatKhmers.org

ឧបាយលែបខាយធ្វើឱ្យសប្បាយភ្លេចស្មារតី ។ មទ្រីអើយ នរណាឡើយនឹងទៅយល់ក្នុងព្រៃ មួយសោត ក្នុងព្រៃពុំដែលស្ងាត់ សឹងមានមនុស្សម្នាវិជ្ជាធរ ព្រានព្រៃឃោគាវចរតាបសឫសី អម្បាលចិត្តនៅនាលោកិយពុំទាន់លុះមគ្គផល កាលបើយល់រូបនាងមទ្រីនេះដើរតែម្នាក់ឯង វានឹងមិនកោតក្រែងនរណាឡើយ វានឹងលួងលោមស្រដីតាមភាសាលោកិយប្រពៃណីនោះ លុះថ្ងៃល្ងាចត្រជាក់ ទើបនាងរកបេះផ្លែឈើ បានដាក់ក្នុងកញ្ជើហើយចេញមក ។ មួយសោត រីអស់ផ្លែឈើសារពើផង ក៏សឹងមានដេរដាសពុំសូវក្រពេកទេ ហើយមានពុំឆ្ងាយ ទៀបៗ នៅអាយក៏សឹងមានអក្ខោ ទន្លាប់ ដង្កោ គុយស្វាយ ចេក អំពៅ ញ្ញៅទាំងឡាយ ក៏សឹងមានទៀបឋានព្រះអាស្រមគួរគិតបារម្ភមកកាន់កូន រវៀសរវាំងក្រែងស្រេកទឹកឃ្លានបាយ ក្រែងភ័យអន្តរាយអ្វីមួយកើតមាន ក៏នឹងបានដឹងបានឮ នេះមិនគិតដូច្នោះឡើយ ព្រងើយកន្តើយ ដើរត្រាច់ទៅលេងក្រសាលសប្បាយក្នុងព្រៃឆ្ងាយ ត្បិតផ្លែឈើទៀងនៅអាយ ពុំសូវមានឱជារស ទៅឆ្ងាយនោះវាសប្បាយ ផ្លែឈើទាំងឡាយ ទំនើងតែនឹងក្រសាលតាមដោយនូវ

Websites: WatKhemaraRatanaram.org or WatKhmers.org

ចំណង់ចិត្តនាង យប់អាធ្រាត្រងងឹត ទើបមកដោយនូវពន្លឺរស្មីព្រះចន្ទ្រ ហើយមកដណ្តឹងសួររកកូន, កូនតើនវណាដឹងជាទៅឯណា នែមទ្រី អើយ ធម្មតាស្រីទាំងឡាយ ទោះមានប្តីមានកូន ថាបើមានបើទៅទីង ណាមួយយូរបន្តិច គេរែងនឹកមកកូនមកប្តីគេខ្លះ នេះម្តងម្តេចឡើយ មទ្រីនាងអើយ នឹងតែនឹងអាលចូលព្រៃ អំពីព្រឹករលះរលាំងភ្លេចភ្លាំង ស្មារតី ឯកូននិងប្តីនៅឯក្រោយ នាងមិនមានចិត្តគិតនឹកដល់តិចឡើយ ទាំងនេះហេតុតែនាងយល់បងនេះ បុណ្យតិចចាករាជ្យសម្បត្តិ ព្រាត់ អំពីព្រះញាតិវង្សាសេនាទាហានគ្នានឡើយ ហើយមកនៅក្នុងព្រៃទ្រង់ ផ្នួសបួសជាតាបសឥសី នឹងស្រដីខាងឯអាណាចក្រពុំបាន ទើបនាង មទ្រីហ៊ានធ្វើដូច្នេះ ទាំងនេះទាំងនោះ ហេតុតែកម្មបងឯងមានមកពី ព្រេង នឹងស្រដីថាអ្វីពុំបានឡើយ ។

បពិត្រអើយ រីព្រះបរមពោធិសត្វ ចាប់ដើមអំពីប្រសព្វនឹង ព្រះនាងមទ្រី សោយរាជ្យសម្បត្តិលុះខ្វាត់មកនៅព្រៃគិរីវង្កតបព៌តនេះ នឹងដែលមានព្រះបន្ទូលអ្វីជាថ្នាំងថ្នាក់ អាក់ព្រះរាជហឫទ័យព្រះនាង ដល់ម្តងនោះពុំមានឡើយ ហើយព្រះនាងមទ្រីសោត នឹងដែលធ្វើអ្វី

Websites: WatKhemaraRatanaram.org or WatKhmers.org

ឱ្យសៅហ្មងឆ្គងនឹងព្រះរាជហឫទ័យនោះគ្មានឡើយ ។ ព្រះអង្គមានព្រះបន្ទូលត្រាស់បន្ទុះថា ចិត្តលោកិយអម្បាលណោះ ហេតុប្រយោជន៍នឹងឱ្យព្រះនាងស្រាក់ស្រាន្តរសាយព្រះសោកបុត្តវិយោគ ព្រាត់ប្រាសចាកពីឱរា លុះស្តេចមានព្រះបន្ទូលនូវប្រការអម្បាលណោះហើយ ទើបស្តេចធ្វើជាខ្វាល់ ឱនព្រះភក្ត្រដាក់ព្រះនេត្រ ប្រែព្រះបិដ្ឋិឱ្យព្រះនាង ហើយផ្តត់ព្រះភ្នែនពែនព្រះបាទស្ងៀមនៅ ។

រីសម្តេចព្រះនាងមទ្រី កាលបើព្រះស្វាមីមានព្រះបន្ទូលដូច្នោះហើយ ព្រះនាងលុតព្រះជង្គង់ លើកកំបង់អញ្ជលីករប្រណម្យឱនព្រះសិរសាចុះ ទទួលយល់ហាក់គ្រាន់ធូរក្នុងព្រះឱរា អម្បាលទុក្ខខ្លោចផ្សាស្រយាលគ្រាន់អធ្យោគ ព្រះសំណោកនោះគ្រាន់រសាយហើយ ព្រះនាងក្រាបទូលថា ៖

ននុ ត្វំ សទ្ទមស្សោសិ យេ សរំ ចាតុមាគតា
សីហស្ស វិនទន្តស្ស ព្យគ្ឃស្ស ច និក្កូជិតំ ។
អហុ បុព្វនិមិត្តំ មេ វិចរន្ត្យា ព្រហាវនេ
ខណិត្តោ មេ ហត្ថា បតិតោ ឧគ្គីវញ្ចាបិ អំសតោ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

តទាហំ ព្យត្ថិតា ភីតា　　ប៉ុថុំ កត្វាន អញ្ជលឹ
សព្វា ទិសា ឧមស្សិស្សំ　　អបិ សោត្ថិ ឥតោ សិយា ។
មា ហេវ នោ រាជបុត្តោ　　ហតោ សីហេន ទីបិនា
ទារកា វា បរាមដ្ឋា　　អច្ឆកោកតរច្ឆិភិ ។
សីយោ ព្យគ្ឃោ ច ទីបិ ច　　តយោ វាឡា វនេ មិតា
តេ មំ បរិយាវុំ មគ្គំ　　តេន សាយម្ហិ អាគតាតិ ។

បពិត្រព្រះរាជស្វាមី អម្ចាស់វិសេសខ្ញុំអើយ ចាប់ដើមអំពីអញខ្ញុំមកនៅជាបាទបរិចារិកាបម្រើ ពុំដែលបានធ្វើឱ្យសៅហ្មងឆ្គងនឹងព្រះនេត្រ ទាស់ព្រះរាជហឫទ័យដល់ម្តងសោះឡើយ ក៏ហេតុតែកម្មអញខ្ញុំបានធ្វើអំពើពុំគាប់ពីមុនមក ដល់ឥឡូវនេះ នាំឱ្យអញខ្ញុំនេះទាស់ឆ្គាំឆ្គងនឹងព្រះរាជហឫទ័យ រីទោសានុទោសផងទាំងពួង អញខ្ញុំសូមទទួលទុកលើសិរសា សូមទ្រង់ព្រះករុណាអត់ទោសបានម្តង ។ មួយសោត អញខ្ញុំបានជាបាត់យូរដល់ម៉្លេះនេះ នាអញខ្ញុំដើរមកពីព្រៃដល់ផ្លូវចង្អៀត ស្រាប់តែពើបពះប្រទះនឹងស្តេចម្រឹគទាំង ៣ គឺ រាជសីហ៍ នូវខ្លាធំ ខ្លាដំបង មកនៅស្កាត់ទទឹងមាគ៌ា នឹងរកផ្លូវជៀសចេញ

ពុំរួចឡើយ ហើយគ្រហឹមគម្រាមនោះមហិមា អញខ្ញុំភិតភ័យថ្នាសមរណ៍ លើកដៃសំពះអង្វរប៉ុន្មាន ៗ ក្តី ក៏ពុំជៀសចេញឡើយ ហើយអញខ្ញុំគិតនឹកដល់អម្ចាស់នូវកូនទាំងពីរ ត្បិតអញខ្ញុំយល់សប្តិយប់មិញនោះពុំល្អ ទើបសំពះអង្វរអស់ទេវតាអារក្សរក្សាព្រៃ សូមឱ្យជួយរក្សាការពារព្រះអង្គនូវកូនទាំងពីរ កុំឱ្យមានអន្តរាយឡើយ ។ អម្ចាស់ខ្ញុំអើយ មិនប៉ុន្តែម្ល៉ោះឡើយ អញខ្ញុំកើតមាននិមិត្តអាក្រក់អស្ចារ្យ គឺជ្រនីកទំពក់ជ្រុះអំពីដៃ កញ្ជើសង្រែកជ្រុះទៅទីទៃ ឈើឯណាមានផ្លែក៏ប្រែខ្វៃជាឥតផ្លែវិញ ។ រីភ្នែកអញខ្ញុំខាងស្តាំមិញក៏កម្រើក មួយសោតដូចព្រះអង្គមានព្រះបន្ទូលនោះ អញខ្ញុំមានអស់ទេវតាក្នុងព្រៃហេមពាន្តជាសាក្សីទិព្វញាណ បានដឹងខុសគាប់នៃអញខ្ញុំមទ្រី ៗ តែងមានស្វាមីភក្តិ មានចិត្តរួមរ័ក្សនឹងព្រះអង្គរៀងមក ទោះបីមទ្រីជួជាតិក៏សឹងជ្រាបក្នុងព្រះរាជហឫទ័យ សូមទ្រង់ព្រះពិនិត្យ បើអញខ្ញុំខុសពិត សូមថ្វាយជីវិតតាមសព្វព្រះរាជហឫទ័យ ។ រីអញខ្ញុំនេះ ប្រណិប័តន៍តាមសុចរិត តែសព្វថ្ងៃពុំចេរនឹងទ្រង់ព្រះមេត្តាប្រោស អត់ទោសអញខ្ញុំមទ្រីក្នុងគ្រានេះម្តងហោង ។

ព្រះមហាសត្វត្រាស់នឹងព្រះនាងមទ្រីត្រឹមប៉ុណ្ណោះ ក៏មិនមានព្រះបន្ទូលអ្វីតទៅទៀត រហូតដល់ព្រះអរុណរះឡើង ។ ឯព្រះនាងទ្រង់ព្រះកន្សែងពិលាប មានប្រការផ្សេង ៗ ថា ៖

អហំ បតិញ្ច បុត្តេ ច អាចរិយមិវ មាណវោ
អនុដ្ឋិតា ទិវារត្តឹ ជដិនី ព្រហ្មចារិនី ។
អជិនានិ បរិទហិត្វា វនមូលផលហារិយា
វិចរាមិ ទិវារត្តឹ តុម្ហំ កាមា ហិ បុត្តកា ។
ឥទំ សុវណ្ណហាលិទ្ទំ អាភតំ បណ្ឌុវេលុវំ
រុក្ខបក្កានិ ចាហាសឹ ឥមេ វោ បុត្តកីឡនា ។
ឥទំ មូឡាលិវត្តកំ សាលុកំ ជិញ្ជរោទកំ
ភុញ្ជ ខុទ្ទេន សំយុត្តំ សហ បុត្តេហិ ខត្តិយ ។
បទុមំ ជាលិនោ ទេហិ កុមុទំ បទ កុមារិយា
មាលិនេ បស្ស នច្ចន្តេ សិវិបុត្តានិ អវ្ហយ ។
តតោ កណ្ហាជិនា យាតិ និសាមេហិ រថេសភ

Websites: WatKhemaraRatanaram.org or WatKhmers.org

មញ្ជុស្សាយ វត្ថុយា អស្សមំ ឧបគច្ឆន្តិយា ។
សមានសុខទុក្ខម្ហា វឌ្ឍា បព្វជិតា ឧភោ
អបិ សិវិបុត្តេ បស្សេសិ ជាលឹ កណ្ហាជិនំ ចុភោ ។
សមណេ ព្រាហ្មណេ នូន ព្រហ្មចរិយបរាយណេ
អហំ លោកេ អភិសសិំ សីលវន្តេ ពហុស្សុតេ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលឹ កណ្ហាជិនំ ចុភោតិ ។

ខ្លួនយើងមិនប្រមាទ ខំសង្វាតតាមមកប្រណិប័តន៍ព្រះរាជស្វាមីនិងកូនគូសំពត់គ្រប់ទិវារាត្រី ពុំដែលឈប់ខាន បីដូចសិស្សតាមប្រណិប័តន៍គ្រូអាចារ្យ ទទ្រង់ជដាប្រព្រឹត្តព្រហ្មចារ្យ ត្រាច់ស្វែងរកអាហារ គឺមើមឈើនិងផ្លែឈើក្នុងព្រៃ មកផ្គត់ផ្គង់ប្រណិប័តន៍រាល់ ៗ ថ្ងៃ ឱកូនកំសត់ម្ដាយអើយ ព្រោះស្រឡាញ់បាទាំងពីរទេតើ ។ នេះរមៀតមានសម្បុរដូចមាស ម្ដាយរកមកបុកលំអិតសម្រាប់ផ្ងូតទឹកឱ្យបា នេះផ្លែព្នៅទុំ ៗ សម្បុររលើបរលង់ ម្ដាយបេះមកឱ្យបាលេង ម្ដាយបានស្រាល់ជ្រើសរើសផ្លែឈើទុំ ៗ ជាច្រើនមុខ យកមកទុកបំរុងឱ្យបាលេង អស់នេះសុទ្ធតែជាល្បែងរបស់កូនសម្លាញ់ ។ បពិត្រ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះបរមក្សត្រដ៏ប្រសើរ នេះគឺក្រឧឪឈូក ផ្លែឈូក ផ្លែក្រចាប់ ប្រឡាក់នឹងទឹកឃ្មុំតែល្មមមានឱជារស សូមព្រះទ្រង់យស ទ្រង់សេពសោយជាមួយនឹងព្រះរាជបុត្រក្នុងកាលឥឡូវនេះឯង ។ បពិត្រអម្ចាស់អើយ សូមព្រះអង្គទ្រង់ព្រះរាជទានផ្កាបទុមទៅបាជាលី ឯផ្កាកុមុទនេះ សូមទ្រង់ព្រះរាជទានឱ្យមេក្រស្នាកុមារី ព្រះអង្គនឹងបានទតព្រះនេត្រកូនទាំងពីរពាក់កម្រងផ្ការាំថ្វាយ សូមព្រះអង្គត្រាស់ហៅព្រះរាជបុត្រទាំងពីរ ឱ្យចេញពីក្នុងបណ្ណសាលាឆាប់ ៗ រ៉ា មេក្រស្នានឹងអាលមកកាន់ម្តាយឯណោះ ។ បពិត្រព្រះបរមក្សត្រសូរ្យវង្ស សូមព្រះអង្គទ្រង់ព្រះសណ្តាប់សំដីមេក្រស្នា ដ៏មានសូរសៀងសំនៀងពីរោះទន់ភ្លន់ គួរឱ្យចង់ស្តាប់ ។ យើងទាំងពីរអង្គកាលគេបំបរបង់ចេញចាកបុរីរដ្ឋ សឹងមានសុខទុក្ខស្មើភាគគ្នា អើព្រះអង្គបានឃើញមេក្រស្នា និងបាជាលីដែរឬទេ ។ ប្រហែលកាលពីជាតិមុនមក អញធ្លាប់ជេរប្រទេចផ្តាសាសមណព្រាហ្មណ៍ អ្នកប្រព្រឹត្តធម៌ត្រឹមត្រូវ ជាអ្នកមានសីល ជាពហុស្សូត្រក្នុងលោកនេះថា កុំឱ្យលោកឃើញបុត្រធីតារបស់ខ្លួន បានជាមកក្នុងថ្ងៃនេះ អញមិនបានជួបមុខចៅជាលីនិងមេក្រស្នា បុត្រទាំងពីរ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឡើយ ។

សូម្បីព្រះនាងមទ្រីទ្រង់ព្រះកន្សែងសោយសោក ជាពន្លឹកដល់ម្ល៉ោះក៏ដោយ ក៏ព្រះមហាសត្វនឹងមានព្រះបន្ទូលដល់មួយព្រះឱស្ឋផងនោះគ្មានឡើយ ។ កាលព្រះមហាសត្វ មិនបានត្រាស់ប្រស្រ័យ ព្រះនាងមានព្រះកាយញាប់ញ័រចំប្រប់ ដើរស្វះស្វែងរកព្រះរាជបុត្រដោយពន្លឺព្រះចន្ទ្រ ស្តេចត្រាច់រត់រកក្នុងទីល្បែងក្រសាលមានដើមជម្ពូព្រឹក្សជាដើម ដែលព្រះរាជកុមារធ្លាប់រត់ក្រសាលលេង ក៏ពុំឃើញ ទើបទ្រង់ព្រះកន្សែងពិលាបរៀបរាប់ ដោយនូវបាទព្រះគាថាទាំងឡាយដូច្នេះថា ៖

ឥមេ តេ ជម្ពុកា រុក្ខា វេទិសា សិន្ទុវារិតា
វិវិធានិ រុក្ខជាតានិ តេ កុមារា ន ទិស្សរេ ។
អស្សត្ថា បនសា ចេមេ និគ្រោធា ច កបិត្ថនា
វិវិធានិ ផលជាតានិ តេ កុមារា ន ទិស្សរេ ។
ឥមេ តិដ្ឋន្តិ អារាមា អយំ សីតូទកា នទី
យត្ថស្សុ បុព្វេ កីឡឹសុ តេ កុមារា ន ទិស្សរេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ភិជានិ បុប្ផជាតានិ    អស្មិំ ឧបរិបព្វតេ
យានស្សុ បុព្វេ ជាវិំសុ    តេ កុមារា ន ទិស្សរេ ។
ភិជានិ ផលជាតានិ    អស្មិំ ឧបរិបព្វតេ
យានស្សុ បុព្វេ កុញ្ជិំសុ    តេ កុមារា ន ទិស្សរេ ។
ឥមេ តេ ហត្ថិកា អស្សា    ពលិពទ្ធា ច នោ ឥមេ
យេហិស្សុ បុព្វេ កីឡិំសុ    តេ កុមារា ន ទិស្សរេតិ ។

កូនអើយ ចាប់ដើមពីថ្ងៃនេះទៅហើយ សមម្ដាយនឹងស្ងាត់ឮតែមាត់សព្ទសត្វយំនៅពាសព្រៃ ហើយម្ដាយនឹងគិតស្រណោះអាឡោះអាល័យ លន្លង់លន្លោចខ្លោចផ្សាក្នុងឱរាក្រៀមក្រំ ម៉្លេះហើយសមម្ដាយនឹងយំសោកសង្រេង ដរាបលុះតែក្ស័យជីវិតទៅហោង ។ កូនអើយ ឬមួយលោកអ្នករត់ទៅលេងសព្វស្ថានល្បែង ដែលតែងនឹងលេងសព្វថ្ងៃទេដឹងអើយ ម៉្លោះហើយព្រះនាងក៏រត់ទៅទាំងរាត្រីរកសព្វស្ថានល្បែង ទ្រង់ព្រះកន្សែងហើយស្រែកហៅថា «ឱកូនពៅម្ដាយទាំងពីរ អ្នកនៅស្ថានឯណា ចូរមកបៅម្ដាយអាយ ម្ដាយមករកអ្នក ម្ដេចឡើយពុំឮមាត់ឆ្លើយមកកាន់ម្ដាយ» ។ ឱអស់សំនួនរូបគោតូច គោធំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ច្រទ្បំនឹងរូបដំរី រូបរទេះផង នូវអស់ផ្កាកម្រងមាលា ដែលកូនស្ងួនពុំងា នាំគ្នាមកលេងចាំផ្លូវម្ដាយ នៅឋានអាយនេះ ។ កូនអើយ ម្ដាយយល់ ហើយទ្រូងម្ដាយស្ទើរប្រេះ ឱថ្ងៃនេះហើយ តើអ្នកនាំគ្នាទៅលេងស្ថាន ឯណាវិញទៀតហើយ ។ កូនអើយ សមអ្នកក្ស័យជីវិតទាំងពីរមែនពិត ដឹងអើយ ។ ម្ល៉ោះហើយព្រះនាងរែងជាទ្រង់ព្រះកន្សែងថ្លែងពិលាប អាណិតអនាថ ខំយាងព្រះបាទរត់រកសព្វស្ថាន មុខគួរឱ្យមានមេត្តា ប្រណី ។ សម្ដេចព្រះមទ្រីស្ដេចត្រាច់រកក្នុងរាត្រីតែមួយព្រះអង្គឯង ស្រែកហៅក្អែង ៗ រកព្រះរាជបុត្រ ព្រះរាជហឫទ័យរន្ធត់ញ័រអស់ ឥន្ទ្រិយ អស់ទាំងសត្វម្រឹគបក្សី ឮហើយសឹងតែភិតភ័យភ្ញាក់ផ្អើល ព្រះនាងទតមៀងមើលស្មានជាព្រះរាជបុត្រ តែពុំយល់ប្រាកដឡើយ ព្រះនាងត្រឡប់វិលមកកាន់ព្រះបរមពោធិសត្វ ហើយក្រាបទូលវិញ ទៀតថា «បពិត្រព្រះរាជស្វាមីអម្ចាស់វិសេសខ្ញុំអើយ ឥឡូវនេះ ខ្ញុំរត់រក កូនទាំងពីរសព្វគ្រប់អស់ឋានល្បែងពុំយល់ឡើយ ពុំដឹងជាទៅឯណា ទោះកាចទោះជា សូមទ្រង់មេត្តាបើកព្រះឱស្ឋបន្ទូលប្រាប់ខ្ញុំម្ចាស់ សោះថប់ពេកឡើយ» ឱអញអើយ បីដូចសត្វអកមានកូនទាំងគូឱ្យ

នៅចាំសំបុក ហើយអាត្មាឯងទៅស្វែងរកចំណីអាហារ ប្រយោជន៍នឹងនាំមកចិញ្ចឹមកូន មកដល់សំបុកហើយ រកកូនពុំឃើញ ហើយជាទុក្ខសោកស្ដាយកូននោះម្ដេចមិញ រីអញខ្ញុំកើតទុក្ខមានឧបមាបីដូច្នោះឯងហោង ។

ព្រះនាងទតព្រះនេត្រ ឃើញអស់ទាំងរូបសំនួនល្បែងរបស់ព្រះរាជបុត្រាបុត្រីនោះហើយ ទើបមានព្រះបន្ទូលជាបាទព្រះគាថាដូច្នេះ ៖

ឥមេ សាមា សសោលូកា ពហុកា កទលីមិគា
យេហិស្សុ បុព្វេ កីឡឹសុ តេ កុមារា ន ទិស្សរេ ។
ឥមេ ហំសា ច កោញ្ចា ច មយុរា ចិត្របេខុណា
យេហិស្សុ បព្វេ កីឡឹសុ តេ កុមារា ន ទិស្សរេតិ ។

ឱ ! អស់សំនួនកូនម្រឹគតូច ៗ រូបទន្សាយ រូបសត្វមៀមនិងរូបសត្វឈ្លូស ក៏មានជាច្រើន ដែលកូនស្ងួនសម្លាញ់ម្ដាយធ្លាប់លេងអំពីមុន នេះគឺសំនួនរូបហង្ស ក្រៀល ក្ងោក ដ៏មានព្រុយកន្ទុយល្អវិចិត្រ សុទ្ធជាល្បែងដែលបាទាំងពីរគាប់ចិត្តលេងអំពីមុន

Websites: WatKhemaraRatanaram.org or WatKhmers.org

ឥឡូវម្តាយពុំបានយល់មុខបាទាំងពីរឡើយ ។

លុះព្រះនាងពុំបានឃើញព្រះរាជបុត្រសម្លាញ់ទាំងពីរ ក្នុងអាស្រមបទហើយ ទើបចេញចាកព្រះអាស្រមបទ រត់ត្រឡប់ចូលទៅកាន់ព្រៃនៃបុប្ផជាតិ ទ្រង់ទតព្រះនេត្ររកសព្វទីនោះ ៗ ហើយត្រាស់ថា៖

ឥមា តា វេឌកុម្ពាយោ បុប្ផិតា សព្វកាលិកា
យត្ថស្សុ បុព្វេ កីឡឹសុ តេ កុមារា ន ទិស្សរេ ។
ឥមា តា បោក្ខរណី រម្មា ចក្កវាកូបកូជិតា
មណ្ឌាលកេហិ សញ្ឆន្នា បទុមុប្បលកេហិ ច
យត្ថស្សុ បុព្វេ កីឡឹសុ តេ កុមារា ន ទិស្សរេតិ ។

នេះគឺស៊ុមទ្រុមគុម្ពឈើតែងមានផ្ការីកគ្រប់រដូវកាល ដែលកុមារទាំងពីរធ្លាប់ក្រសាលលេង នេះគឺស្រះបោក្ខរណី ជាទីរីករាយក្សេមក្សាន្ត តែងឮសូរសព្ទយំរងាវ នៃសត្វចាក្រពាកដ៏ដេរដាសដោយផ្កាមណ្ឌាលក៍ ផ្កាបទុមនិងផ្កាឧប្បលដែលកុមារទាំងពីរធ្លាប់ក្រសាលលេងអំពីមុន តែម្តាយគយគន់រកបាទាំងពីរពុំឃើញឡើយ ។

លុះព្រះនាងរត់រកសព្វកន្លែងពុំឃើញហើយ ទើបស្តេចត្រឡប់ទៅកាន់សំណាក់ព្រះមហាសត្វជាព្រះរាជស្វាមីទៀត ទ្រង់ទតឃើញព្រះអង្គទ្រង់ជ្រប់ព្រះភក្ត្រ ពុំមានព្រះបន្ទូលដូច្នោះ ទើបព្រះនាងក្រាបទូលតវ៉ាថា ៖

ន តេ កដ្ឋានិ ភិន្នានិ ន តេ ឧទកមាភតំ
អគ្គិបិ តេ ន ហាសិតោ កិន្នុ មន្ទោវ ឈាយសិ ។
បិយោ បិយេន សង្គម្ម សមោហំ ព្យបហញ្ញតិ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលឹ កណ្ហាជិនំ ចុភោតិ ។

បពិត្រព្រះរាជស្វាមី សព្វថ្ងៃរៀងមក ព្រះអង្គកាប់ឧសដងទឹកយកមកទុក បង្កាត់ភ្លើងទុកក្នុងជើងក្រាន ថ្ងៃនេះព្រះអង្គឥតធ្វើអ្វីសោះឡើយ បានតែគង់សុបសៅច្រងូវ កិរិយារបស់ព្រះអង្គនេះ មិនជាទីគាប់ចិត្តអញខ្ញុំឡើយ ពីមុន ៗ មកព្រះវេស្សន្តររាជស្វាមីហ្នឹងហើយ ជាទីស្រឡាញ់ពេញចិត្តនៃអញខ្ញុំ មិនមានអ្នកដ៏ទៃក្រៃលែងជាងនេះឡើយ គ្រាន់តែបានយល់ព្រះភក្ត្រ ក៏ភ្លេចសេចក្តីនឿយព្រួយលំបាកទាំងអស់មកក្នុងថ្ងៃនេះ អញខ្ញុំបានយល់ព្រះភក្ត្រ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអង្គហើយ ក៏នៅតែមិនរសាយសេចក្ដីសោក ព្រោះមិនបានជួបមុខកូនទាំងពីរ គឺចៅជាលីនិងមេក្រស្នានោះឡើយ ។

កាលសម្ដេចព្រះនាងមទ្រី ក្រាបទូលតវ៉ាយ៉ាងនេះហើយ សម្ដេចព្រះមហាសត្វ ក៏នៅតែគង់នៅស្ងៀម ពុំមានព្រះបន្ទូលដល់មួយព្រះឱស្ឋឡើយ ម្ល៉ោះហើយព្រះនាងរែងជាទុក្ខធ្ងន់ក្រៃលែង ទ្រង់សោយសោកខ្សឹកខ្សួលរំជួលអស់អង្គប្រាណ ហាក់ដូចមេមាន់ដែលត្រូវគេប្រហារ ព្រះនាងត្រាច់រត់ទៅកាន់កន្លែងមុននោះទៀត ហើយវិលមកកាន់សំណាក់ព្រះមហាសត្វវិញ ក្រាបបង្គំទូលសួរថា ៖

ន ខោ នោ ទេវ បស្សាមិ យេន តេ នីហដា មតា
កាកោលាបិ ន វស្សន្តិ មតា មេ នូន ទារកា ។
ន ខោ នោ ទេវ បស្សាមិ យេន តេ នីហដា មតា
សកុណាបិ ន វស្សន្តិ មតា មេ នូន ទារកាតិ ។

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ អញខ្ញុំមិនឃើញកូនទាំងពីរសោះឡើយ ចុះអ្នកណានាំយកទៅ ឬមួយស្លាប់ទៅហើយ សូម្បីសត្វក្អែកព្រៃនិងសត្វបក្សីផងទាំងឡាយ ក៏ស្ងាត់ជ្រងំ មិន

Websites: WatKhemaraRatanaram.org or WatKhmers.org

ឮយំរងាវរកគ្នាសោះឡើយ កូនរបស់អញខ្ញុំ ប្រាកដជាស្លាប់មែនដឹង អើយ ។

កាលព្រះនាងក្រាបទូលសួរយ៉ាងនេះហើយ ព្រះមហាសត្វ ក៏ពុំមានព្រះបន្ទូលដល់មួយព្រះឱស្ឋឡើយ ។ ព្រះនាងរែងជាទុក្ខជា សោកខ្លោចផ្សា ខំស្វះស្វែងរកព្រះរាជបុត្រាបុត្រី ស្តេចរត់ទៅកាន់ទី តំបន់នោះ ៗ យ៉ាងរហ័សរួសរាន់ ដូចសន្ទុះខ្យល់ដល់ ៣ គ្រា ។ មាន សេចក្តីដំណាលថា ទីឋានទាំងពួងដែលសម្តេចព្រះរាជមទ្រីស្តេច ត្រាច់រត់រកព្រះរាជបុត្រក្នុង ១ រាត្រីប៉ុណ្ណោះ បើនឹងលាតត្រដាងចេញ ទៅជាចម្ងាយផ្លូវដល់ ១៥ យោជន៍ ។ លុះវេលារាត្រីភ្លឺស្វាង ព្រះ អរុណរះឡើងហើយ សម្តេចព្រះនាងមទ្រី ក៏ស្តេចត្រឡប់មកកាន់ សំណាក់សម្តេចព្រះមហាសត្វវិញ ស្តេចឈរទ្រង់ព្រះកន្សែង សោយ សោកយ៉ាងក្រៃលែង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រនូវបាទព្រះគាថាដូច្នេះថា ៖

សា តត្ថ បរិទេវិត្វា　　បព្វតានិ វនានិ ច
បុនទេវស្សមំ គន្ត្វា　　សាមិកស្សន្តិ រោទតិ ។
ន ខោ នោ ទេវ បស្សាមិ　　យេន តេ នីហដា មតា
កាកោលាបិ ន វស្សន្តិ　　មតា មេ នូន ទារកា ។
ន ខោ នោ ទេវ បស្សាមិ　　យេន តេ នីហដា មតា
សកុណាបិ ន វស្សន្តិ　　មតា មេ នូន ទារកា ។
ន ខោ នោ ទេវ បស្សាមិ　　យេន តេ នីហដា មតា
វិចរន្តី រុក្ខមូលេសុ　　បព្វតេសុ គុហាសុ ច
ឥតិ មទ្ទី វរារោហា　　រាជបុត្តី យសស្សិនី
ពាហា បគ្គយ្ហ កន្ទិត្វា　　តត្ថេវ បតិតា ឆមាតិ ។

ភិក្ខវេ ម្នាលភិក្ខុទាំងឡាយអើយ ភិក្ខុអើយមុខគួរឱ្យអាសូរប្រណី សម្តេចព្រះភគវតី ព្រះនាងមទ្រីវរលក្ខណ៍អគ្គជាយា ដ៏មានសិរីសួស្តី ព្រះនាងរត់រកព្រះរាជបុត្រាបុត្រីសស្រាក់ ទាំងយប់រាត្រី រកសព្វស៊ុមទ្រុមគុម្ពឈើ ច្រកភ្នំ និងព្រៃព្រឹក្សាផងពុំយល់ឡើយ ហើយព្រះ

នាងវិលមកកាន់ព្រះអាស្រម ក្រាបទូលព្រះបរមរាជស្វាមី ទ្រង់ព្រះកន្សែងសោយសោក ព្រះអង្គពុំមានព្រះបន្ទូលដល់មួយព្រះឱស្ឋឡើយ ហើយព្រះនាងរត់ទៅរកវិញទៀត ព្រះនាងរត់ទៅរត់មកជាច្រើនគ្រា រីឯអាហារ ព្រះនាងពុំបានសោយឡើយ ហើយទ្រង់ព្រះកន្សែងដង្ហោយស្រែកហៅ ដ៏មានព្រះសូរសៀងសម្លេងនោះ ឮទូទ័រទៅសព្វព្រៃព្រឹក្សា សត្វផងឮហើយក៏ភិតភ័យភ្ញាក់ផ្អើលគគឹក ព្រះនាងឮសន្ធឹក ក៏ទ្រង់ឈរស្តាប់ យល់ជាក់ជាសត្វហើយ ព្រះនាងក៏អួលអាក់ក្នុងព្រះឱរា ទ្រង់ព្រះកន្សែងថា ‹‹ឱមាសថ្លៃម្តាយអើយ ម្តាយស្រមៃឮសន្ធឹកគិតថាជាកូន ឥឡូវសោះសូន្យមិនយល់ស្ងួន ទន់អស់ទាំងខ្លួនស្ងួតក កូនអើយ សមម្តាយមិនមានជីវិតរស់នៅទេដឹងអើយ›› ។ ម្លោះហើយព្រះនាងវិលមកកាន់ព្រះបរមពោធិសត្វវិញ ព្រះនាងលើកព្រះករគក់ព្រះឱរា ទ្រង់ព្រះកន្សែងថ្លែងព្រះពិលាប ដ៏មានព្រះសូរសៀងខ្សាបខ្សោះអស់ព្រះកាយពល ទល់ទុក្ខវេទនាពុំស្រយាលតាំងអំពីព្រលប់ពុំបានឈរឈប់ លុះដល់ព្រះអាទិត្យឧទ័យរស្មីស្វាងបំព្រាងឡើងហើយមានព្រះអង្គព្រះនាងនោះ ញ័ររន្ធត់ចំប្រប់នឹងទប់ពុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

បាន ព្រះនាងខំលើកព្រះហស្តទាំងសងខាងដាក់លើសិរសីខំតម្រង់ព្រះស្មារតី ក្រាបទូលថា «បពិត្រអម្ចាស់វិសេសខ្ញុំអើយ ដើមឡើយអញខ្ញុំមទ្រីមានសេចក្តីប្រាថ្នាក្នុងចិត្ត គិតថានឹងពិភក្តិរក្សាប្រណិប័តន៍ល្អងធូលីព្រះបាទនូវកូនទាំងពីរ ដរាបលុះតែអស់ជីវិត ឥឡូវនេះ កូនខ្ញុំទាំងពីរក៏បាត់ទៅហើយ អញខ្ញុំខំរត់រកតាំងពីព្រលប់ដល់ថ្ងៃនេះហើយ, ឱ! អម្ចាស់ខ្ញុំអើយ វិទុក្ខអញខ្ញុំធ្ងន់ពន់ប្រមាណ ទប់ពុំបានឡើយ អញខ្ញុំសូមក្រាបលា ឱ! នរណាអើយ នឹងមកប្រណិប័តន៍អម្ចាស់ឱ្យដូចជាអញខ្ញុំនេះ» ។ ព្រះនាងមានព្រះបន្ទូលតែម្ល៉ោះហើយលុះផុតព្រះបន្ទូល ក៏ដួលសន្លប់ទៅលើក្រឡាមហាប្រឹថពី នៅទីចំពោះព្រះភក្ត្រព្រះបរមពោធិសត្វ ដ៏កាលនោះឯងហោង ។

វីព្រះបរមពោធិសត្វ ព្រះអង្គយល់ព្រះនាងដួលសន្លប់ទៅដូច្នេះហើយ ព្រះអង្គភិតភ័យក្នុងព្រះរាជហឫទ័យ ទ្រង់ព្រះចិន្តាថា ព្រះនាងក្ស័យព្រះជន្មា ស្តេចយាងចុះម្ទីម្នាពីលើព្រះបរមសាលា ទ្រង់សោយព្រះសោកាថា «ឱះ!ឱអនិច្ចាមទ្រីអើយ ម្តេចឡើយមកក្ស័យព្រះជន្មា ចោលបងតែម្នាក់ឯង នៅកណ្តាលព្រៃភ្នំនេះ នរណាឡើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

នឹងជួយលើកព្រះសពនាង មទ្រីអើយបើក្សយព្រះជន្មនៅនគរនាយទៅវ៉ា អស់ព្រះញាតិវង្សាក្នុងនគរទាំងពីរ នឹងមកប្រជុំព្រមគ្នាជួយលើកព្រះសពនាង ឥឡូវនេះនៅតែបងម្នាក់ឯងកណ្ដោងកំព្រា សមបងនឹងក្ស័យ ប្រល័យជីវិតតាមនាងជាប្រាកដមិនទេឡើយ›› ។ លុះព្រះអង្គរំសាយព្រះសោកហើយ ទ្រង់ព្រះចិន្តាថា ‹‹មទ្រីក្ស័យជីវិតមែនពិតឬដូចម្ដេចអេះ ? ត្រូវអញត្រួតមើលឱ្យបានដឹងពិតប្រាកដសិន›› ។ ទើបស្ដេចដោះឡើង ទ្រង់យកព្រះហស្តស្ដាំស្ទាបព្រះឧរារត្នរបស់ក្សត្រី ទ្រង់ជ្រាបថា មទ្រីនេះគ្រាន់តែសន្លប់ទេ ទើបស្ដេចយកទឹកមកហើយទ្រង់ផ្ទមលើកត្រកងព្រះសិរសា ដាក់តម្កល់លើព្រះឱរ្ឫរត្នរបស់ព្រះអង្គ ។ រីព្រះបរមពោធិសត្វ ចាប់ដើមតាំងពីព្រះអង្គទ្រង់ព្រះផ្នួសជាគំរប់ ៧ ខែហើយ ពុំដែលប៉ះពាល់ព្រះអង្គព្រះនាងដល់ម្ដងឡើយទើបតែថ្ងៃនេះ ព្រះអង្គភិតភ័យរលះរលាំងភ្លេចព្រះស្មារតី ទ្រង់ស្ទាបព្រះឧរាក្សត្រី ថ្នមព្រះសិរសីដាក់លើព្រះឱរ្ឫរត្ន ហើយទ្រង់យកទឹកកុណ្ឌីស្រោចស្រង់ ស្រឡាបព្រះអង្គព្រះនាង ។ ទើបព្រះនាងភ្ញាក់ព្រះស្មារតីភ្លឹករលឹកព្រះអង្គ ទតព្រះនេត្រយល់ព្រះរាជស្វាមី ហើយក៏រំកិល

ព្រះអង្គថយចេញ ទូលដណ្តឹងសួរអំពីព្រះរាជបុត្រទាំងពីរថា ‹‹បពិត្រព្រះរាជស្វាមីអម្ចាស់ខ្ញុំអើយ រីព្រះរាជបុត្រាបុត្រីរបស់ព្រះអង្គ តើទៅឯណាទៅ ?››។ ព្រះបរមពោធិសត្វមានព្រះបន្ទូលប្រាប់ថា ‹‹មទ្រីទេវីអើយ រីកូនយើងទាំងពីរនោះ បងបានឱ្យទៅធ្វើជាខ្ញុំព្រាហ្មណ៍ម្នាក់ ពីថ្ងៃម្សិលរួចទៅហើយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាន្ទូវបាទព្រះគាថាដូច្នេះ ៖

តមជ្ឈ បត្តំ រាជបុត្តឹ ឧទកោជាភិសិញ្ចថ
អស្សត្ថំ ជំ វិជិត្វាន អថ ជំ ឯតទព្រវីតិ ។

កាលនោះ ព្រះបាទស្រីវេស្សន្តរបវររាជឫសី ទ្រង់យកទឹកប្រោះព្រំសព្វព្រះកាយព្រះនាងមទ្រីរាជបុត្រី ដែលដល់នូវវិសញ្ញីបាត់ព្រះស្មារតីក្នុងសំណាក់ព្រះអង្គ លុះព្រះនាងភ្ញាក់ព្រះអង្គ មានព្រះស្មារតីឡើងវិញហើយ ទើបទ្រង់មានព្រះបន្ទូលប្រាប់សេចក្តីនោះ ឱ្យព្រះនាងបានជ្រាបជាខាងក្រោយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

កាលព្រះនាងមទ្រី បានស្តាប់ព្រះបន្ទូលព្រះរាជស្វាមីហើយ ទើបក្រាបទូលថា «បពិត្រព្រះសម្មតិទេព ក្សត្រថ្លៃប្រសើរអើយ បើព្រះអង្គទ្រង់ព្រះរាជទានព្រះរាជបុត្តទៅព្រាហ្មណ៍ កាលអញខ្ញុំខំរត់រកកូនទាំងយំសោកសស្រាក់ អស់មួយយប់ទាល់ភ្លឺ ម្តេចក៏ព្រះអង្គពុំមានព្រះបន្ទូលប្រាប់អញខ្ញុំអំពីដើមសោះ អញខ្ញុំព្រួយចិត្តជាទុក្ខ» ។ សម្តេចព្រះមហាសត្វត្រាស់តបថា ៖

អានិយេនេវ តេ មទ្ទិ ទុក្ខំ នក្ខាតុមិច្ឆិសំ
ទលិទ្ទោ យាចកោ វុឌ្ឍោ ព្រាហ្មណោ ឃរមាគតោ ។
តស្ស ទិន្នា មយា បុត្តា មទ្ទិ មា ភាយិ អស្សស
មំ បស្ស មទ្ទិ មា បុត្តេ មា ពាឡ្ហំ បរិទេវយិ ។
លច្ឆាម បុត្តេ ជីវន្តា អរោគា ច ភវាមសេ
បុត្តេ បសុញ្ច ធញ្ញញ្ច យញ្ច អញ្ញំ ឃរេ ធនំ ។
ទជ្ជា សប្បុរិសោ ទានំ ទិស្វា យាចកមាគតេ
អនុមោទាហិ មេ មទ្ទិ បុត្តកេ ទានមុត្តមន្តិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះនាងមទ្រីអើយ ព្រះនាងបន្ទោសបងនេះក៏គួរមែនពិត តែគឺមោះបងគិតថា មទ្រីនេះទើបមកពីព្រៃ ហើយមានបើជាទុក្ខមកពីនាយ បើនឹងប្រាយប្រាប់ដោយពិត តាំងពីដំបូងហើយ នាងរឹងជាទុក្ខធ្ងន់ក្រៃលែងទប់ទល់ពុំបាន នឹងបែកដើមទ្រូងស្លាប់ទៅ ហេតុនេះទើបបងធ្វើជាខឹង ។ នាងមទ្រីអើយ ព្រាហ្មណ៍ស្នូមចាស់ជាអ្នកកំសត់អត់ឃ្លាន បានមកដល់លំនៅយើងហើយ ឥតមានទេយ្យទានអ្វី ទើបបងយកបុត្រាបុត្រីឱ្យទៅជាទានព្រាហ្មណ៍ ចូរនាងកុំភ័យព្រួយបារម្ភ ចូរខំតាំងចេតនាត្រេកអរសោមនស្ស ចូរនាងមើលបងតាងកូន កុំបីចងចិត្តស្នេហាជាទុក្ខសោកខ្លាំងពេកឡើយ បើយើងឥតរោគមានជីវិតរស់នៅគង់តែនឹងបានឃើញកូនយើងជាប្រាកដ ។ នាងមទ្រីអើយ កុំថាឡើយតែកូនប្រុស-ស្រី សត្វ-ធញ្ញជាតិស្រូវអង្ករ និងទ្រព្យមានវិញ្ញាណ ឥតវិញ្ញាណដទៃទៀត ដែលមាននៅក្នុងផ្ទះ ធម្មតាសប្បុរសដែលលោកប្រាថ្នាប្រយោជន៍ខ្ពង់ខ្ពស់ កាលបានឃើញស្នូមមកដល់ផ្ទះហើយលោកអាចពុះទ្រូងរូងយកប្រមាត់បេះដូង លើកឱ្យជាទានតាមដែលស្នូមត្រូវការ ។ នាងមទ្រីអើយ ចូរនាងអនុមោទនាត្រេកអរ នឹងបុត្ត-

Websites: WatKhemaraRatanaram.org or WatKhmers.org

ទានដ៏ឧត្តមខ្ពង់ខ្ពស់បំផុតរបស់បងនេះហោង ។

ទើបព្រះនាងក្រាបបង្គំទូល ថ្វាយអនុមោទនាដោយព្រះគាថាដូច្នេះ ៖

អនុមោទាមិ តេ ទេវ បុត្តកោ ទានមុត្តមំ
ឧត្វា ចិត្តំ បសាទេហិ ភិយ្យោ ទានំ ទទោ ភវ ។
យោ ត្វំ មច្ឆេរភូតេសុ មនុស្សេសុ ជនាធិប
ព្រាហ្មណស្ស អទា ទានំ សិរីនំ រដ្ឋវឌ្ឍនោតិ ។

បពិត្រព្រះសម្មតិទេពក្សត្រប្រសើរអើយ អញខ្ញុំព្រះអង្គសូមអនុមោទនាបុត្តទានដ៏ឧត្តមរបស់ព្រះអង្គ អម្ចាស់អើយ រីកូនអញខ្ញុំនេះ អញខ្ញុំខំថែរក្សាតាំងពីនៅក្នុងភគ៌ ១០ ខែ លុះត្រាតែប្រសូតចេញមកហើយ ក៏អញខ្ញុំចិញ្ចឹមបីបាច់រក្សាផ្ងូតទឹក បញ្ចុកបបរបាយអស់កិច្ចការផងទាំងឡាយ អញខ្ញុំសូមថ្វាយអនុមោទនានឹងបុត្តទានរបស់ព្រះអង្គ សូមឱ្យព្រះអង្គបានសម្រេចព្រះពោធិញ្ញាណ បានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ ស្រង់សត្វផងទាំងឡាយ ដ៏អនាគតកាល កុំបីឃ្លាតឡើយ ហើយឯព្រះអង្គសោត ចូរមានព្រះរាជហឫទ័យចម្រើន

Websites: WatKhemaraRatanaram.org or WatKhmers.org

នូវព្រះបីតិត្រេកអរនឹងព្រះបិយបុត្តទាន ឱ្យជាភិយ្យោភាពឡើងទៅហោង ។ បពិត្រព្រះអង្គជាអធិបតីនៃប្រជាជន ព្រះអង្គតែងធ្វើសេចក្ដីចម្រើនដល់អ្នកស្រីពិរាស្រ្ដ គង់នៅក្នុងចំណោមមនុស្ស ដែលប្រកបដោយសេចក្ដីកំណាញ់ស្វិតស្វាញ ក៏ព្រះអង្គអាចព្រះរាជទានបុត្រាបុត្រី ឱ្យទៅជាទានព្រាហ្មណ៍បានសម្រេចដូចព្រះប្រាថ្នា ។

ព្រះបរមពោធិសត្វ ក៏មានព្រះបន្ទូលថា ‹‹សាធុ សាធុ›› មទ្រីអើយ ពាក្យនាងនេះពីរោះ ៗ ក្រៃពេក មទ្រីអើយ ថាបើបងមិនត្រេកអរនឹងទាននោះ ម្ដេចឡើយក៏នឹងកើតមានអស្ចារ្យ កក្រើករំពើកញាប់ញ័រទាំងក្រឡាមហាប្រឹថពី នាកាលបងឱ្យកូនទៅជាទាន អំពីថ្ងៃម្សិលមិញនោះឯង ។ លំដាប់នោះ សម្ដេចនាងមទ្រី ក្រាបទូលថ្លែងហេតុអស្ចារ្យទាំងអម្បាលណោះ ដែលព្រះនាងបានទតឃើញជាក់ស្ដែងរួចហើយ ទើបព្រះនាងទ្រង់អនុមោទនាទានបារមី នៃព្រះមហាសត្វ ក្រាបទូលសូត្រជាបាទព្រះគាថាដូច្នេះ ៖

ឆិន្នាឆិតា តេ បឋវី　　　សទ្ទោ តេ តិទិវង្គតោ
សមន្តា វិជ្ជុតា អាគូ　　　គិរីនំវ បដិស្សុតាតិ ។

នាកាលអញខ្ញុំទៅស្វែងរកផ្លែឈើក្នុងព្រៃ អំពីព្រឹកម្សិលមិញនោះ យល់ចម្លែកអស្ចារ្យ ទាំងមហាមេឃក៏មមីរទូទឹម ទាំងភ្នំក៏កក្រើក មានសូរស័ព្ទលាន់កងរំពង ទៅដល់ឋានសួគ៌ទេវលោកនាយផ្លេកបន្ទោរ ពុំដូចកាលសឹងដ៏ដាលច្រវាត់ អម្ចាស់ខ្ញុំអើយ នេះមិនគឺអ្នកឯណាឡើយ គឺសេចក្ដីអស្ចារ្យទានបារមី នៃព្រះអង្គមិនទេឡើយ ។

តស្ស តេ អនុមោទន្តិ ឧភោ នារទបព្វតា
ឥន្ទោ ច ព្រហ្មា ច បជាបតី ច
សោមោ យមោ វេស្សវណោ ច រាជា
សព្វេ ទេវានុមោទន្តិ តាវតឹសា សឥន្ទកា
ឥតិ មទ្ទី វរារោហា រាជបុត្តី យសស្សិនី
វេស្សន្តរស្ស អនុមោទិ បុត្តកេ ទានមុត្តមន្តិ ។

កាលនោះ អស់ទាំងពួកទេវតាទាំងពីរក្រុម ឋិតនៅភ្នំនារទបព៌ត ព្រមទាំងព្រះឥន្ទ្រ ព្រះព្រហ្ម ស្ដេចប្រជាធិបតី ព្រះចន្ទ្រ ព្រះយមរាជ ព្រះវេស្សវ័ណមហារាជ និងពពួកទេវតានៅនាឋាន

Websites: WatKhemaraRatanaram.org or WatKhmers.org

តាវត្តិង្ស មានព្រះឥន្ទ្រាធិរាជជាអធិបតី សឹងមានបីតិត្រេកអរ ថ្វាយសព្ទសាធុការអនុមោទនាព្រមគ្នាថា ៖ ‹‹បពិត្រព្រះវេស្សន្តរក្សត្រថ្លៃប្រសើរអើយ ព្រះអង្គបរិច្ចាគទានហើយ ដោយប្រពៃក្រៃលែង›› ។

ឯសម្តេចព្រះនាងមទ្រីរត្នកញ្ញាដ៏ទ្រង់លក្ខណាប្រសើរ ជាព្រះរាជបុត្រីដ៏ទ្រង់យស មានព្រះរាជហឫទ័យស័គ្រស្មោះ ថ្វាយអនុមោទនាចំពោះបុត្តទានបារមី ដ៏ឧត្តមរបស់ព្រះបរមពោធិសត្វមហាបុរសរ័ត្នព្រមលួមជាមួយគ្នា ដោយនូវប្រការអម្បាលនោះហោង ។

មទ្ទីបព្វំ និដ្ឋិតំ បពិត្រអើយ អាត្មាភាពសម្តែងថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតក កណ្ឌមទ្រីបព្វទី ៩ នេះមិញដ៏ប្រដាប់ប្រដានីទៅនូវគាថា ៩០ ព្រះគាថា ឯវំ ក៏ចប់បរិបូណ៌សមគួរដោយនូវវេលានេះឯងហោង ៕ល៚

(ចប់កណ្ឌមទ្រីបព្វ ទី ៩ តែប៉ុណ្ណោះ)

---

Websites: WatKhemaraRatanaram.org or WatKhmers.org

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**ភិក្ខុ គិច្ចកិរតោ ឡាយ រិន**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

**លោកគ្រូ ធម្មនាថ ផនប្រសិទ្ធិ៍**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមវិបសាយ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង




Websites: WatKhemaraRatanaram.org or WatKhmers.org